ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# គីមីវិទ្យា

មេរៀនសង្ខេប និងលំហាត់គំរូ
សម្រាប់ជាជំនួយដល់សិស្សថ្នាក់ទី១២
ឆ្នាំសិក្សា ២០១៤ - ២០១៥



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

# អារម្ភកថា

មេរៀនសង្ខេប និងលំហាត់គំរូនៅក្នុងឯកសារនេះ គឺគ្រាន់តែជាជំនួយស្មារតីដល់អ្នកសិក្សាគីមីវិទ្យាថ្នាក់ទី១២តែប៉ុណ្ណោះ វាមិនមែនជាឯកសារពេញលេញតាមកម្មវិធីសិក្សាថ្នាក់ទី១២ទាំងស្រុងនោះទេ។

ខ្លឹមសារនៃមេរៀននីមួយៗមានភ្ជាប់លំហាត់គំរូដើម្បីមានភាពងាយស្រួលចំពោះសិស្សក្នុងការសិក្សាស្រាវជ្រាវ។

ខ្លឹមសារនៅក្នុងមេរៀនសង្ខេបនេះផ្តោតសំខាន់លើ និយមន័យ ច្បាប់ និងរូបមន្តសំខាន់ៗ ដើម្បីឱ្យអ្នកសិក្សាងាយយល់ និងចងចាំ ព្រមទាំងអាចយកទៅអនុវត្ត ក្នុងការដោះស្រាយលំហាត់បាន។ ម៉្យាងវិញទៀត នៅក្នុងឯកសារនេះបានកែលម្អនូវចំណុចខ្វះខាតមួយចំនួននៅក្នុងសៀវភៅសិក្សាគោលមុខវិជ្ជាគីមីវិទ្យារបស់ក្រសួងអប់រំ យុវជន និងកីឡាបោះពុម្ពលើកទី៤ ឆ្នាំ២០១២។

នៅចុងបញ្ចប់មេរៀនសង្ខេបមួយចំនួនមានលំហាត់គំរូ ដើម្បីពង្រឹងចំណេះដឹង និងជំនាញដោះស្រាយលំហាត់របស់អ្នកសិក្សា។ រាល់ដំណោះស្រាយនៃលំហាត់នីមួយៗបានបង្ហាញពីការប្រើប្រាស់ប្រព័ន្ធខ្នាត និងការគណនាតាមវិធានលេខមានន័យ។

ដើម្បីឱ្យឯកសារនេះកាន់តែមានសង្គតិភាព និងល្អប្រសើរ យើងខ្ញុំរង់ចាំទទួលនូវការរិះគន់ដើម្បីកែលម្អពីលោកគ្រូ អ្នកគ្រូ និងអ្នកសិក្សាទាំងឡាយដោយក្តីសោមនស្សរីករាយបំផុត។


**អ្នករៀបរៀង**

ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា

**អ្នកកែលម្អ**

១. លោក បណ្ឌិត កែវ វ៉ាន់ធឿន

២. លោក ណុប វុឍ

៣. លោក ប៉ែន សំភា

៤. កញ្ញា ថ្លាង សុវិយា





facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

# មាតិកា

**ជំពូក ១ ស៊ីនេទិចគីមី**

មេរៀនទី ១ ល្បឿនប្រតិកម្មគីមី

មេរៀនទី ២ កត្តាជះឥទ្ធិពលលើល្បឿនប្រតិកម្ម

**ជំពូក ២ សមាសធាតុក្នុងសូលុយស្យុងទឹក និងកម្លាំងអន្តរម៉ូលេគុល**

មេរៀនទី ១ សមាសធាតុក្នុងសូលុយស្យុងទឹក

មេរៀនទី ២ កម្លាំងអន្តរម៉ូលេគុល

**ជំពូក ៣ អាស៊ីត-បាស**

មេរៀនទី ១ ទ្រឹស្តីអាស៊ីត-បាស

មេរៀនទី ២ ប្រតិកម្មអាស៊ីត និងបាស

មេរៀនទី ៣ សូលុយស្យុងទឹក និងpH

មេរៀនទី ៤ អត្រាកម្មអាស៊ីត-បាស

**ជំពូក ៤ លំនឹងគីមី**

មេរៀនទី ១ ធម្មជាតិនៃលំនឹងគីមី

មេរៀនទី ២ ការរំកិលលំនឹង

**ជំពូក ៥ គីមីសរីរាង្គ**

មេរៀនទី ១ អេស្ទែ ខ្លាញ់ និងប្រេង

មេរៀនទី ២ ស្រលាយអាលីផាទិចអាសូត

មេរៀនទី ៣ សមាសធាតុប្រហើរ



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

# ជំពូកទី១ ស៊ីនេទិចគីមី

## មេរៀនទី១ ល្បឿនប្រតិកម្មគីមី

ស៊ីនេទិចគីមីគឺជាការសិក្សាអំពីបម្រែបម្រួលល្បឿនប្រតិកម្ម។

### ១. កន្លាពេលក្នុងប្រតិកម្មគីមី

### ១.១ ប្រតិកម្មរហ័ស

ប្រតិកម្មរហ័ស គឺជាប្រតិកម្មដែលប្រព្រឹត្តទៅក្នុងរយៈពេលដ៏ខ្លីមួយ។

ឧទាហរណ៍: - $Ag^{+}(aq) + Cl^{-}(aq) \rightarrow AgCl(s)$

- $Cu^{2+}(aq) + OH^{-}(aq) \rightarrow Cu(OH)_2(s)$

### ១.២ ប្រតិកម្មយឺត

ប្រតិកម្មយឺត គឺជាប្រតិកម្មដែលប្រព្រឹត្តទៅច្រើនវិនាទី នាទី ឬច្រើនម៉ោង។

ឧទាហរណ៍: ឌីស្មូតកម្មអ៊ីយ៉ុងត្យូស៊ុលផាត $S_2O_3^{2-}$ក្នុងមជ្ឈដ្ឋានអាស៊ីត ឲ្យផលជា S និង$SO_2$។




$$1 \times \quad S_2O_3^{2-} + 6H^{+} + 4e^{-} \longrightarrow 2S + 3H_2O$$
$$1 \times \quad S_2O_3^{2-} + H_2O \longrightarrow 2SO_2 + 2H^{+} + 4e^{-}$$
$$2S_2O_3^{2-} + 4H^{+} \longrightarrow 2S + 2SO_2 + 2H_2O$$

ជាទូទៅប្រតិកម្មយឺតជាកម្មវត្ថុក្នុងការសិក្សាស៊ីនេទិច

### ១.៣ ប្រតិកម្មយឺតបំផុត

ប្រតិកម្មយឺតបំផុតគឺជាប្រតិកម្មដែលប្រព្រឹត្តទៅច្រើនថ្ងៃ ច្រើនខែ ឬច្រើនឆ្នាំ។

ឧទាហរណ៍៖ ប្រតិកម្មបំបែកទឹកអុកស៊ីសែនេ $H_2O_2$




$$1\times \quad H_2O_2 + 2H^{+} + 2e^{-} \rightarrow 2H_2O$$
$$1\times \quad H_2O_2 \rightarrow O_2 + 2H^{+} + 2e^{-}$$
$$2H_2O_2 \rightarrow O_2 + 2H_2O$$

### ២. ល្បឿនប្រតិកម្មគីមី

### ២.១ ល្បឿនកំណរអង្គធាតុកកើត

ក-សិក្សាពិសោធន៍



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

គេលាយសូលុយស្យុង $H_2O_2$ជាមួយសូលុយស្យុង KI គេឃើញសូលុយស្យុងប្រែជាពណ៌ក្រហមត្នោតដោយសារកកើត $I_2$ ។




$$\begin{array}{l|l} 1\times & H_2O_2 + 2H^+ + 2e^- \longrightarrow 2H_2O \\ 1\times & 2I^- \longrightarrow I_2 + 2e^- \\ \hline & H_2O_2 + 2I^- + 2H^+ \longrightarrow I_2 + 2H_2O \end{array}$$

## ខ-ល្បឿនមធ្យមកំណ $I_2$

**និយមន័យ** ល្បឿនមធ្យមនៃកំណ $I_2$នៅចន្លោះពេល $t_1$ទៅ $t_2$ គឺជាផលធៀបរវាងបម្រែបម្រួលកំហាប់ $I_2$ ជាមួយបម្រែបម្រួលរយៈពេល t ។

យើងបានរូបមន្ត៖ $$V_m = \frac{[I_2]_2 - [I_2]_1}{t_2 - t_1} = \frac{\Delta[I_2]}{\Delta t}$$

**បកស្រាយតាមក្រាប៖** ល្បឿនមធ្យមនៃកំណ I2នៅចន្លោះពេល t1ទៅ t2 មានតម្លៃស្មើនឹងមេគុណប្រាប់ទិសនៃបន្ទាប់កាត់ $M_1$និង $M_2$




យើងបានរូបមន្ត៖ $$V_m = \frac{|HM_2|}{|HM_1|} = \frac{\Delta[I_2]}{\Delta t}$$

## លំហាត់គំរូ

ថ្មកំបោរ $CaCO_3$ (កាល់ស្យូមកាបូណាត) មានប្រតិកម្មជាមួយ HCl (អាស៊ីតក្លរីឌ្រិច)តាមសមីការ

$CaCO_3(s) + 2HCl(aq) \rightarrow CaCl_2(aq) + CO_2(g) + H_2O(l)$

នៅខណៈ t = 15 s កំហាប់ $CaCl_2$កើតបាន $1.8 \times 10^{-3}mol.L^{-1}$និងនៅខណៈ t = 30 s កំហាប់ $CaCl_2$ កើតបាន $3.13 \times 10^{-3}mol.L^{-1}$ ។ចូរកំណត់ល្បឿនមធ្យមនៃកំណកាល់ស្យូមក្លរួ នៅចន្លោះពេលខាងលើ ។

## ចម្លើយ

កំណត់ល្បឿនមធ្យមកំណ$CaCl_2$

សមីការ $CaCO_3(s) + 2HCl(aq) \rightarrow CaCl_2(aq) + CO_2(g) + H_2O(l)$

តាមរូបមន្ត៖ $$V_{m(CaCl_2)} = \frac{[CaCl_2]_2 - [CaCl_2]_1}{t_2 - t_1}$$

ដោយ កំហាប់ $[CaCl_2]_1$នៅខណៈ $t_1 = 15s$ គឺ $1.8 \times 10^{-3}mol.L^{-1}$

កំហាប់ $[CaCl_2]_2$ នៅខណៈ $t_2 = 30s$ គឺ $3.13 \times 10^{-3}mol.L^{-1}$



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

$$V_{m(CaCl_2)} = \frac{3.13\times10^{-3} - 1.8\times10^{-3}}{30-15} = 0.089\times10^{-3} = 8.9\times10^{-5}\ mol.L^{-1}.s^{-1}$$

ដូចនេះ $V_{m(CaCl_2)}=8.9\times10^{-5}\ mol.L^{-1}.s^{-1}$

### គ-ល្បឿនខណៈកំណ $I_2$

**និយមន័យ៖** ល្បឿនខណៈនៃកំណ $I_2$នៅខណៈពេល t គឺជាលីមីត នៃល្បឿនមធ្យម កាលណាបម្រែបម្រួលរយៈពេលខិតទៅរកសូន្យ។

**រូបមន្ត** $V_t = \lim\limits_{\Delta t\to 0}\frac{[I_2]_2-[I_2]_1}{t_2-t_1} = \lim\limits_{\Delta t\to 0}\frac{\Delta[I_2]}{\Delta t}$ ឬ $V_t = \left(\frac{d[I_2]}{dt}\right)_t$

**បំណកស្រាយតាមក្រាប៖** ល្បឿនខណៈ នៃកំណ មានតម្លៃស្មើនឹងមេគុណប្រាប់ទិស នៃបន្ទាត់ប៉ះខ្សែកោងត្រង់ចំណុច M និងអាប់ស៊ីស t ។

$$V_t = \frac{|HT_2|}{|HT_1|} = \frac{\Delta[I_2]}{\Delta t}$$




## ២.២ ល្បឿនបំបាត់អង្គធាតុប្រតិករ

### ក-ល្បឿនមធ្យមបំបាត់$H_2O_2$

និយមន័យ៖ ល្បឿនមធ្យមបំបាត់ $H_2O_2$នៅចន្លោះ ពេល $t_1$ ទៅ $t_2$ គឺជាផលធៀបរវាងបម្រែបម្រួល កំហាប់ $H_2O_2$ ជាមួយនឹងបម្រែបម្រួលរយៈពេល t យើងបានរូបមន្ត

$$V_m = -\frac{[H_2O_2]_2-[H_2O_2]_1}{t_2-t_1} = -\frac{\Delta[H_2O_2]}{\Delta t}$$




### ខ-ល្បឿនខណៈបំបាត់$H_2O_2$

**និយមន័យ៖** ល្បឿនខណៈបំបាត់ $H_2O_2$ នៅ ខណៈពេល t គឺជាលីមីតនៃល្បឿនមធ្យម កាលណាបម្រែបម្រួលរយៈពេលខិតទៅរកសូន្យ។ យើងបានរូបមន្ត៖

$$V_t = \lim_{\Delta t\to 0} -\frac{[H_2O_2]_2-[H_2O_2]_1}{t_2-t_1} = \lim_{\Delta t\to 0} -\frac{\Delta[H_2O_2]}{\Delta t}$$

ឬ $V_t = -\left(\frac{d[H_2O_2]}{dt}\right)_{t_1}$



ជាទូទៅ៖ កំហាប់គិតជា $mol.L^{-1}$ រយៈពេលគិតជា $min$ ឬ $s$

និងល្បឿនគិតជា $mol.L^{-1}.min^{-1}$ ឬ $mol.L^{-1}.s^{-1}$ ។

## ៣. ការទូទៅ និង និយមន័យ

សមីការតាងប្រតិកម្ម

$$R \longrightarrow P$$

(អង្គធាតុប្រតិករ) (អង្គធាតុកកើតឬផលិតផល)

### ៣.១ ការវិវត្តន៍កំហាប់អង្គធាតុប្រតិករ ( R ) និង កំហាប់អង្គធាតុកកើត ( P )

- កំហាប់អង្គធាតុប្រតិករថយចុះជាអនុគមន៍ទៅនឹងរយៈពេល ហើយនៅពេលអានន្ត កំហាប់អង្គធាតុប្រតិករវិវត្តទៅរកកំហាប់អានន្តដែរ $[R]_\infty$ ។

- កំហាប់អង្គធាតុកកើតកើនឡើងជាអនុគមន៍ទៅនឹងកំណើនរយៈពេល ហើយនៅពេលអានន្ត កំហាប់អង្គធាតុកកើតវិវត្តទៅរកកំហាប់អានន្តដែរ $[P]_\infty$ ។

**ជាទូទៅ៖** ក្នុងពេលប្រតិកម្ម កំហាប់អង្គធាតុប្រតិករថយចុះ ឯកំហាប់អង្គធាតុកកើតកើនឡើង។

- ពេលពាក់កណ្ដាលប្រតិកម្ម $t_{\frac{1}{2}}$ គឺជាពេលដែលត្រូវនឹងកំហាប់ផលិតផល កកើតបានពាក់កណ្ដាល ឬ កំហាប់អង្គធាតុប្រតិករអស់ពាក់កណ្ដាល។

- កំហាប់ផលិតផលកកើតបានពាក់កណ្ដាល $[P]_{t_{1/2}} = \frac{[P]_\infty}{2}$

-កំហាប់អង្គធាតុប្រតិករនៅសល់ពាក់កណ្ដាល

$$[R]_{t_{\frac{1}{2}}} = \frac{[R]_0 - [R]_\infty}{2}$$

### ៣.២ ការវិវត្តន៍ល្បឿនបំបាត់អង្គធាតុប្រតិករ (R) និងល្បឿនកំណអង្គធាតុកកើត (P)

- ល្បឿនបំបាត់អង្គធាតុប្រតិករថយចុះ ជាអនុគមន៍ទៅនឹងកំណើនរយៈពេល ហើយខ្សែកោង $[R] = f(t)$ ខិតជិតអាស៊ីមតូតដេក $[R]_\infty$ ។

- ល្បឿនកំណអង្គធាតុកកើតថយចុះ ជាអនុគមន៍ ទៅនឹងកំណើនរយៈពេល ហើយនៅពេលអានន្តខ្សែកោង $[P] = f(t)$ ខិតជិតអាស៊ីមតូតដេក $[P]_\infty$ ។




ខ្សែកោងល្បឿនបំបាត់អង្គធាតុប្រតិករ




ខ្សែកោងល្បឿនកំណអង្គធាតុកកើត



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

# មេរៀនទី២ កត្តាជះឥទ្ធិពលលើល្បឿនប្រតិកម្ម

## ១. កត្តាទំហំភាគល្អិត

ពិសោធន៍៖ គេដាក់ដុំ $CaCO_3$ទំហំធំល្មមចំនួន 20g , ដុំ $CaCO_3$ តូចៗ20g និងម្សៅ $CaCO_3$ 20g ទៅក្នុងសូលុយស្យុង HCl ក្នុងកែវបីផ្សេងគ្នាតាមរៀង ដែលកែវនីមួយៗមានកំហាប់ 1 M មាឌ 200 mL ។




**សង្កេត៖** ប្រតិកម្មដោយប្រើម្សៅ $CaCO_3$ ជាមួយHCl លឿនជាងប្រើដុំតូចៗ និងលឿនជាដុំធំតាមរៀង។

**សន្និដ្ឋាន៖** ល្បឿនប្រិតកម្មអាស្រ័យលើទំហំភាគល្អិត។ ទំហំភាគល្អិតនៃអង្គធាតុប្រតិករ កាន់តែតូច ល្បឿនប្រតិកម្មកាន់តែលឿន។

**បកស្រាយ៖** កាលណាទំហំភាគល្អិតកាន់តែតូច នាំឲ្យមានការទង្គិចប្រសិទ្ធ រវាងអង្គធាតុប្រតិករកាន់តែច្រើន ជាហេតុធ្វើឲ្យល្បឿនប្រតិកម្មកាន់តែលឿន។

## ២. កត្តាកំហាប់អង្គធាតុប្រតិករ

**ពិសោធន៍៖** រៀបចំកែវបីដាក់សូលុយស្យុង KI ដែលមានកំហាប់ខុសៗគ្នា ដោយមានបន្ថែមសូលុយស្យុង $H_2SO_4$ បន្តិច។ បន្ទាប់មកចាក់ $H_2O_2$ ក្នុងបរិមាណស្មើគ្នា កំហាប់ស្មើគ្នាចូលក្នុងកែវទាំងបីក្នុងពេលតែមួយ។




សមីការ៖ $H_2O_2 + 2I^- + 2H^+ \rightarrow I_2 + 2H_2O$

**សង្កេត៖** កែវដែលមានកំហាប់ KI ខាប់ខ្លាំង ($I^-$ ច្រើន) នោះការឡើងពណ៌ក្រហមត្នោតនៃ $I_2$ លឿនជាង

កែវដែលមានកំហាប់ KI រាវ ឬ $I^-$ តិច។



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

**សន្និដ្ឋាន៖** ល្បឿនកំណអង្គធាតុកកើត ឬល្បឿនបំបាត់អង្គធាតុប្រតិករ កើនកាលណាកំហាប់អង្គធាតុប្រតិករកើនឡើង។

**បំណកស្រាយ៖** កំហាប់អង្គធាតុប្រតិករកើន នាំឲ្យមានទង្គិចប្រសិទ្ធច្រើន ដូចនេះល្បឿនបំបាត់ ឬល្បឿនកំណក៏កើនឡើងដែរ។

## ៣. កត្តាសម្ពាធ

សម្ពាធមានឥទ្ធិពលតែទៅលើប្រព័ន្ធប្រតិកម្មដែលមានភាពរូបជាឧស្ម័នតែប៉ុណ្ណោះ។ កាលណាសម្ពាធកើនឡើង នាំឲ្យចំនួនទង្គិចប្រសិទ្ធកើនឡើងដែរ នោះល្បឿនប្រតិកម្មកើនឡើង។

ឧទា. ទង្វើអាម៉ូញាក់តាមលំនាំហេបើត្រូវការសីតុណ្ហភាព និងសម្ពាធខ្ពស់ចំពោះមុខកាតាលីករដែក។

$$N_2(g) + 3H_2(g) \underset{\text{សម្ពាធខ្ពស់}}{\overset{Fe}{\rightleftharpoons}} 2NH_3(g)$$




**សន្និដ្ឋាន៖** កាលណាសម្ពាធកើន នាំឲ្យការកកើតអាម៉ូញាក់ក៏កើនដែរ។

**បំណកស្រាយ៖** កាលណាសម្ពាធកើន នាំឲ្យម៉ូលេគុលឧស្ម័ននៅកៀកគ្នា ជាហេតុធ្វើឲ្យមានទង្គិចប្រសិទ្ធកើនឡើង។ ដូចនេះល្បឿនកំណអង្គធាតុកកើត កើនឡើង។

## ៤. កត្តាសីតុណ្ហភាព

**ពិសោធន៍៖** បំពង់សាកពីរ A និង B ដាក់សូលុយស្យុង I⁻ ប្រហែល ¼ នៃបំពង់សាកដោយមានលាយសូលុយស្យុង $H_2SO_4$ បន្តិច។ បន្ទាប់មក យកបំពង់សាក A ដាក់ត្រាំក្នុង ទឹកកក និងបំពង់សាក B ត្រាំក្នុងទឹកក្តៅ។ ចាក់សូលុយស្យុង $H_2O_2$ ប្រហែល ¼ ដែរ ទៅក្នុង បំពង់សាកទាំងពីរខាងលើក្នុងពេលដំណាលគ្នា។




**សង្កេត៖** ចូរកំណត់កម្លាំងអន្តរម៉ូលេគុលនិងសម្ព័ន្ធអ៊ីដ្រូសែ នៃគូក្នុងសមាសធាតុខាងក្រោម៖

**បកស្រាយ៖** នៅពេលសីតុណ្ហភាពកើន ភាគល្អិត (ម៉ូលេគុល អាតូម ឬអ៊ីយ៉ុង) ធ្វើចលនាកាន់តែលឿន នាំឲ្យមានទង្គិចប្រសិទ្ធកាន់តែច្រើន។ដូចនេះ ល្បឿននៃប្រតិកម្មកាន់តែលឿនដែរ។



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

## ៥. កត្តាកាតាលីករ

### ៥.១ កាតាលីករ

**ពិសោធន៍៖** គេមានបំពង់សាកពីរ A និង B ដែលមានដាក់ $H_2O_2$ ប្រហែល ¼ នៃបំពង់សាកនោះ។ គេពុំឃើញមានបាតុភូតអ្វីកើតឡើងទេ។ ប៉ុន្តែប្រសិនបើគេបន្ថែមបរិមាណបន្តិចនៃ $MnO_2$ ចូលក្នុង បំពង់សាក A ។







**សង្កេត៖** វត្តមាន $MnO_2$ ក្នុងបំពង់សាក A គេឃើញមានពពុះឧស្ម័នកើតឡើង និងអាចធ្វើឲ្យរងើកភ្លើងធូបឆេះច្រាល។

គ្មានវត្តមាន $MnO_2$ ក្នុងបំពង់សាក B គេគ្មានឃើញបាតុភូតអ្វីកើតឡើងទេ។

**សន្និដ្ឋាន៖** $MnO_2$ ជាកាតាលីករ។ ដូចនេះកាតាលីករ គឺជាសារធាតុដែលធ្វើឱ្យប្រតិកម្មកើតឡើងកាន់តែលឿន។

**បកស្រាយ៖** វត្តមាន $MnO_2$ ក្នុង$H_2O_2$ (បំពង់សាកA) បានជួយបំបែកជាឧស្ម័នអុកស៊ីសែន និងទឹក ដោយ$MnO_2$ រក្សាបរិមាណនៅដដែល។

⁕ **កាតាលីករ** គឺជាសារធាតុដែលជួយពន្លឿនល្បឿនប្រតិកម្មគីមីកើតឯង ហើយវាកើតឡើងវិញដោយគ្មានបាត់បង់លក្ខណៈគីមីនៅពេលប្រតិកម្មចប់។

### ៥.២ កាតាលីស

កាតាលីស គឺជាអំពីនៃកាតាលីករទៅលើប្រតិកម្មគីមី។

គេចែកកាតាលីសជាបីប្រភេទ៖

- កាតាលីសអូម៉ូសែន ៖ គឺជាកាតាលីសដែលកាតាលីករ និងអង្គធាតុប្រតិករមានផាសដូចគ្នា។

ឧទា. $H_2O_2(aq) \xrightarrow{Fe^{2+}(aq)} H_2O(l) + ½ O_2(g)$

អង្គធាតុប្រតិករជាសូលុយស្យុង ឯកាតាលីករក៏ជាសូលុយស្យុងដែរ។

- កាតាលីសអេតេរ៉ូសែន ៖ ជាកាតាលីសដែលកាតាលីករនិងអង្គធាតុប្រតិករមានផាសខុសគ្នា។

ឧទា. $H_2O_2(aq) \xrightarrow{MnO_2(s)} H_2O(l) + ½ O_2(g)$

អង្គធាតុប្រតិករជាសូលុយស្យុង ឯកាតាលីករក៏ជាអង្គធាតុរឹង។

- កាតាលីសអង់ស៊ីម ៖ ជាកាតាលីសដែលកាតាលីករជាអង់ស៊ីម (ដូចជាប្រូតេអ៊ីនដែលបង្កឡើង ពីភាវរស់)។

ឧទា.  $H_2O_2(aq) \xrightarrow{\text{អង់ស៊ីមក្នុងថ្លើម}} H_2O(l) + \frac{1}{2} O_2(g)$

## ៥.៣ លក្ខណៈកាតាលីករ

### នាទីលើស៊ីនេទិច

កាតាលីករអាចបង្កើនល្បឿនតែទៅលើប្រតិកម្មទាំងឡាយណាដែលប្រព្រឹត្តទៅតាមទែម៉ូឌីណាមិចប៉ុណ្ណោះ។ ចំពោះប្រតិកម្មដែលមានភាពរាំងខ្ទប់ស៊ីនេទិច គ្មានកាតាលីករណាអាចធ្វើឲ្យប្រតិកម្មប្រព្រឹត្តទៅបានទេ។

ឧទា.  $Cu(s) + HCl(aq) \rightarrow$ គ្មានប្រតិកម្មកើតឡើងទេ

### បាតុភូតវិសេសភាព

កាលណាកាតាលីករមួយមានសកម្មភាពលើប្រតិកម្មតែមួយច្បាស់លាស់គេនិយាយថា កាតាលីករមានវិសេសភាពចំពោះប្រតិកម្មនោះ។

ឧទា.  ដេស៊ីដ្រូសែនកម្មអេតាណុល

$$CH_3CH_2OH(aq) \xrightarrow{Cu} CH_3CHO(aq) + H_2(g)$$

$$CH_3CH_2OH(aq) \xrightarrow{Al_2O_3(400^0C)} CH_2 = CH_2 + H_2O(g)$$

### កាតាលីករ ជាទូទៅគេប្រើក្នុងបរិមាណតិច

ឧទា. ប្រតិកម្មផលិតអាម៉ូញាក់ដោយសំឡីដែក។ គេអាចប្រើសំឡីដែកក្នុងបរិមាណតិចធៀបនឹងបរិមាណអង្គធាតុប្រតិករ និងប្រើក្នុងរយៈពេលយូរអង្វែងមិនងាយដូរ។

### កាតាលីករចូលរួមប្រតិកម្ម

ឧទា. ប្រតិកម្មឌីស្មូតកម្ម $H_2O_2$ ដោយប្រើ កាតាលីករ $Fe^{2+}$។

- ដំបូង

$$\begin{array}{l|l} 1\times & H_2O_2 + 2H^+ + 2e^- \rightarrow 2H_2O \\ 2\times & Fe^{2+} \rightarrow Fe^{3+} + 1e^- \\ \hline & 2Fe^{2+} + H_2O_2 + 2H^+ \rightarrow 2Fe^{3+} + 2H_2O \quad (1) \end{array}$$

- បន្ទាប់

$$\begin{array}{l|l} 2\times & Fe^{3+} + 1e^- \rightarrow Fe^{2+} \\ 1\times & H_2O_2 \rightarrow O_2 + 2H^+ + 2e^- \\ \hline & 2Fe^{3+} + H_2O_2 \rightarrow 2Fe^{2+} + O_2 + 2H^+ \quad (2) \end{array}$$




- បូក (1) និង(2) :

$$\begin{array}{ll} 2Fe^{2+} + H_2O_2 + 2H^+ \rightarrow 2Fe^{3+} + 2H_2O & (1) \\ 2Fe^{3+} + H_2O_2 \rightarrow 2Fe^{2+} + O_2 + 2H^+ & (2) \\ \hline 2H_2O_2 \rightarrow 2H_2O + O_2 & (3) \end{array}$$

❈ ដូចនេះអ៊ីយ៉ុង$Fe^{2+}$ ចូលរួមប្រតិកម្ម តែក្រោយប្រតិកម្មចប់ វាកកើតឡើងវិញដដែល។



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

## ៥.៤ ស្វ័យកាតាលីស

**និយមន័យ៖** ស្វ័យកាតាលីសគឺជាកាតាលីសដែលអង្គធាតុកកើតមាននាទីជាកាតាលីករក្នុងប្រតិកម្ម។

ឧទា. រេដុកម្មអ៊ីយ៉ុងពែម៉ង់កាណាត $MnO_4^-$ ដោយអាស៊ីតអុកសាលិច $H_2C_2O_4$

$$\begin{array}{l|l} 2\times & MnO_4^- + 8H^+ + 5e^- \longrightarrow Mn^{2+} + 4H_2O \\ 5\times & H_2C_2O_4 \longrightarrow 2CO_2 + 2H^+ + 2e^- \\ \hline & 2MnO_4^- + 5H_2C_2O_4 + 6H^+ \xrightarrow{Mn^{2+}} 2Mn^{2+} + 10CO_2 + 8H_2O \end{array}$$

❋ អ៊ីយ៉ុង$Mn^{2+}$ មានតួនាទីជាកាតាលីករក្នុងប្រតិកម្មខាងលើ។

## ៥.៤ ផលប្រយោជន៍នៃកាតាលីករចំពោះឧស្សាហកម្ម

កាតាលីសមានសារៈសំខាន់យ៉ាងខ្លាំងចំពោះឧស្សាហកម្មគឺមី

(1) ចំណេញពេលវេលា ថវិកា

(2) បង្កើនផលិតផល និង

(3) សម្រាំងផលិតផល



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

# ជំពូកទី២ សមាសធាតុក្នុងសូលុយស្យុងទឹក និងកម្លាំងអន្តរម៉ូលេគុល
## មេរៀនទី១ សមាសធាតុក្នុងសូលុយស្យុងទឹក

### ១. ការបំបែកអ៊ីយ៉ុងក្នុងទឹក

សមាសធាតុភាគច្រើនរលាយក្នុងទឹកបំបែកជាអ៊ីយ៉ុង ។

ឧទា. $NaCl\ (s) \xrightarrow{H_2O} Na^+\ (aq) + Cl^-\ (aq)$

$Ca(NO_3)_2\ (s) \xrightarrow{H_2O} Ca^{2+}\ (aq) + 2NO_3^-\ (aq)$

$HCl\ (g) + H_2O(l) \rightarrow H_3O^+\ (aq) + Cl^-\ (aq)$

### ១.១ ប្រតិកម្មបង្កើតកករ

សមាសធាតុអ៊ីយ៉ុងមួយចំនួនមិនរលាយក្នុងទឹកទេ។

សមាសធាតុរលាយឬមិនរលាយក្នុងទឹកមានបង្ហាញក្នុងតារាងធាតុរលាយ ។

ឧទា. $AgNO_3(aq) + NaCl\ (aq) \rightarrow AgCl\ (s) + NaNO_3\ (aq)$

$2NaOH(aq) + CuSO_4(aq) \rightarrow Cu(OH)_2(s) + Na_2SO_4(aq)$

### ១.២ សមីការអ៊ីយ៉ុងសម្រួល

សមីការអ៊ីយ៉ុងសម្រួលជាសមីការដែលសរសេរតែប្រភេទគីមីទាំងឡាយណាដែលរងនូវបម្រែបម្រួលគីមីក្នុងលំនាំប្រតិកម្ម។

ឧទា- $AgNO_3(aq) + NaCl\ (aq) \rightarrow AgCl(s) + NaCl\ (aq)$ (សមីការម៉ូលេគុល(

$Ag^+(aq) + NO_3^-(aq) + Na^+\ (aq) + Cl^-\ (aq) \rightarrow AgCl\ (s) + Na^+\ (aq) + Cl^-\ (aq)$
(សមីការអ៊ីយ៉ុងសព្វ(

$Ag^+(aq) + Cl^-\ (aq) \rightarrow AgCl\ (s)$ (សមីការអ៊ីយ៉ុងសម្រួល)

### ២. អ៊ីយ៉ុងកម្ម

អ៊ីយ៉ុងកម្ម ជាលំនាំបំបែកជាអ៊ីយ៉ុងនៃសារធាតុរលាយដោយអំពើនៃសារធាតុរំលាយ។ កាល ណា សមាសធាតុអ៊ីយ៉ុងរលាយ អ៊ីយ៉ុងត្រូវបានផ្ដាច់ចេញពីគ្នា ហើយត្រូវហ៊ុំព័ទ្ធដោយម៉ូលេគុលសារធាតុរំលាយ(ឧទា-ទឹក) ។

ឧទា- $NaCl\ (s) \rightarrow Na^+\ (aq) + Cl^-\ (aq)$

$HCl\ (g) + H_2O\ (l) \rightarrow H_3O^+\ (aq) + Cl^-\ (aq)$






facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

### ៣. អ៊ីយ៉ុងអ៊ីដ្រូញ៉ូម ( $H_3O^+$ )

ទឹកចាប់យកអ៊ីយ៉ុង $H^+$ (ប្រូតុង( ពីអាស៊ីត បង្កើតបានជាអ៊ីយ៉ុងអ៊ីដ្រូញ៉ូម ($H_3O^+$) ។

ឧទា. $HCl\ (g) \xrightarrow{H_2O} H^+\ (aq) + Cl^-\ (aq)$ (1)

$H^+\ (aq) + H_2O\ (l) \rightarrow H_3O^+\ (aq)$ (2)

ជាសរុប $HCl\ (g) + H_2O\ (l) \rightarrow H_3O^+\ (aq) + Cl^-\ (aq)$

### ៤. អេឡិចត្រូលីតខ្លាំង និងអេឡិចត្រូលីតខ្សោយ

- សារធាតុឲ្យផលជាអ៊ីយ៉ុងនិងចម្លងចរន្តអគ្គិសនីក្នុងសូលុយស្យុងទឹក ជាអេឡិចត្រូលីត។
- សារធាតុមិនឲ្យផលជាអ៊ីយ៉ុង និងមិនចម្លងចរន្តអគ្គិសនី ក្នុងសូលុយស្យុងទឹក មិនមែនជាអេឡិចត្រូលីតទេ ។

អេឡិចត្រូលីតខ្លាំង ជាសារធាតុទាំងឡាយណាដែលបំបែកជាអ៊ីយ៉ុងទាំងស្រុងក្នុងទឹក។

ឧទា. បាសខ្លាំង អាស៊ីតខ្លាំង អំបិលរលាយសព្វក្នុងទឹក

$Ba(OH)_2(s) \xrightarrow{H_2O} Ba^{2+}(aq) + 2OH^-(aq)$

$HCl\ (g) + H_2O\ (l) \rightarrow H_3O^+\ (aq) + Cl^-\ (aq)$

$NaCl\ (s) \xrightarrow{H_2O} Na^+\ (aq) + Cl^-\ (aq)$

អេឡិចត្រូលីតខ្សោយ ជាសារធាតុទាំងឡាយណាដែលបំបែកជាអ៊ីយ៉ុងដោយផ្នែកក្នុងទឹក។

ឧទា. បាសខ្សោយ អាស៊ីតខ្សោយ

$NH_3(g) + H_2O(l) \rightarrow NH_4^+(aq) + OH^-(aq)$

$CH_3COOH\ (aq) + H_2O\ (l) \rightarrow H_3O^+\ (aq) + CH_3COO^-\ (aq)$



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

# មេរៀនទី២ កម្លាំងអន្តរម៉ូលេគុល

## ១. ការប្រៀបធៀបសមាសធាតុអ៊ីយ៉ុង និងសមាសធាតុកូវ៉ាឡង់

| សមាសធាតុអ៊ីយ៉ុង | សមាសធាតុកូវ៉ាឡង់ |
|---|---|
| - ភាគច្រើនជាអង្គធាតុរឹង ឬក្រាម<br>- ភាគច្រើនបង្កពីលោហៈ និងអលោហៈ<br>- មានសីតុណ្ហភាពរលាយ និងរំពុះខ្ពស់<br>- ដង់ស៊ីតេខ្ពស់ | - ភាគច្រើនជាអង្គធាតុរាវ ឬឧស្ម័ន<br>- ភាគច្រើនបង្កពីអលោហៈ និងអលោហៈ<br>- មានសីតុណ្ហភាពរលាយ និងរំពុះទាប<br>- ដង់ស៊ីតេទាប |

## ២. អ៊ីយ៉ុងមានបន្ទុកផ្ទុយគ្នាប្រទាញគ្នាទៅវិញទៅមក

- សមាសធាតុអ៊ីយ៉ុងផ្សំឡើងពីអ៊ីយ៉ុងវិជ្ជមាននិងអវិជ្ជមាន។អ៊ីយ៉ុងដែលមានបន្ទុកផ្ទុយគ្នាប្រទាញគ្នាទៅវិញទៅមកបង្កើតបានជាកម្លាំងអ៊ីយ៉ុង (កម្លាំងអេឡិចត្រូស្តាទិច)។
- អ៊ីយ៉ុងដែលមានទំហំតូចចូលផ្សំគ្នាបង្កើតជាសមាសធាតុមានចំណុចរំពុះខ្ពស់ជាងអ៊ីយ៉ុងដែលមានទំហំធំ។

  ឧទា. NaCl មានចំណុចរំពុះខ្ពស់ជាង KCl ។
- សមាសធាតុបង្កពីអ៊ីយ៉ុងដែលមាន
  បន្ទុកធំមានចំណុចរំពុះខ្ពស់ជាងសមាសធាតុបង្កពីអ៊ីយ៉ុងដែលមានបន្ទុកតូច។

  ឧទា. $CaCl_2$មានចំណុចរំពុះខ្ពស់ជាង NaCl ។

## ៣. កម្លាំងអន្តរម៉ូលេគុល

- កម្លាំងប្រទាញគ្នាទៅវិញទៅមករវាងម៉ូលេគុលនិងម៉ូលេគុលហៅថា កម្លាំងអន្តរម៉ូលេគុល ។
- កម្លាំងនេះអាចជាកម្លាំងឌីប៉ូល-ឌីប៉ូល និងកម្លាំងឡុងដុន ។ កម្លាំងទាំងពីរនេះអាចកើតមាននៅពេលវានៅជិតគ្នា។កម្លាំងនេះខ្សោយកាលណាម៉ូលេគុលនៅឆ្ងាយពីគ្នាខ្លាំង ឬមានសីតុណ្ហភាពជិតតម្លៃសូន្យដាច់ខាត ( 0 K = – 273 °C ) ។
- ម៉ូលេគុលដែលមានចំណុចរំពុះខ្ពស់ជាង មានកម្លាំងអន្តរម៉ូលេគុលខ្លាំងជាង។

## ៤. កម្លាំងឡុងដុន

កម្លាំងឡុងដុនគឺ ជាកម្លាំងប្រទាញរវាងម៉ូលេគុល និងម៉ូលេគុលដែលមិនប៉ូលែ ។ ម៉ូលេគុលដែលមានម៉ាស់កាន់តែធំ ឬមានអេឡិចត្រុងកាន់តែច្រើន នោះមានកម្លាំងប្រទាញរវាងម៉ូលេគុល និងម៉ូលេគុលកាន់តែខ្លាំង។ កម្លាំងប្រទាញកាន់តែខ្លាំង ចំណុចរលាយ ឬចំណុចរំពុះកាន់តែខ្ពស់។



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

ឧទា. $C_3H_8$មានចំណុចរំពុះខ្ពស់ជាង $CH_4$។ ទោះយ៉ាងណាក៏ដោយ កម្លាំងរបាយឡុនដុន មានលក្ខណៈខ្សោយជាងគេក្នុងចំណោមកម្លាំងអន្តរម៉ូលេគុលទាំងអស់។

ដូចនេះ ជាទូទៅគេពិចារណាទៅលើកម្លាំងអន្តរកម្មមួយនេះតែក្នុងករណីម៉ូលេគុលមិនប៉ូលែប៉ុណ្ណោះ។

## ៥. កម្លាំងឌីប៉ូល-ឌីប៉ូល

- ម៉ូលេគុលឌីប៉ូលជាម៉ូលេគុលដែលអាតូមក្នុងម៉ូលេគុលមានអេឡិចត្រូអវិជ្ជមានខុសគ្នា។
- កម្លាំងឌីប៉ូល-ឌីប៉ូល កើតឡើងរវាងប៉ូលវិជ្ជមាននៃម៉ូលេគុលមួយ ជាមួយប៉ូលអវិជ្ជមាននៃម៉ូលេគុលមួយទៀត ។
- កាលណាម៉ូលេគុលកាន់តែប៉ូលែ កម្លាំងឌីប៉ូល-ឌីប៉ូលកាន់តែខ្លាំង ។
- កាលណាកម្លាំងឌីប៉ូល-ឌីប៉ូលកាន់តែខ្លាំង នោះចំណុចរលាយនិងចំណុចរំពុះនៃសមាសធាតុ នោះកាន់តែខ្ពស់។
- កម្លាំងឌីប៉ូល-ឌីប៉ូល ធំជាងកម្លាំងរបាយឡុនដុន។ គេអាចហៅ កម្លាំងរបាយឡុនដុនថាជាកម្លាំង ឌីប៉ូលអន្ទង។

## ៦. សម្ព័ន្ធអ៊ីដ្រូសែន

ជាកម្លាំងអន្តរម៉ូលេគុលកើតឡើងរវាងអាតូមអ៊ីដ្រូសែនក្នុងម៉ូលេគុលមួយ ជាមួយអាតូមមួយ ក្នុងម៉ូលេគុលមួយផ្សេងទៀតដែលមានកម្រិតអេឡិចត្រូអវិជ្ជមានធំ(មានធាតុ N, O, និង F(។

កម្លាំង អន្តរកម្មនេះ សរសេរជា៖ A – H … B ឬ A – H … A (A និងB អាចជា N, O, ឬ F(។

ឧទា.



**លំហាត់គំរូ**

ចូរកំណត់កម្លាំងអន្តរម៉ូលេគុលនិងសម្ព័ន្ធអ៊ីដ្រូសែ នៃគូក្នុងសមាសធាតុខាងក្រោម៖

ក) HBr និង $H_2S$ ខ) $Cl_2$ និង $CBr_4$ គ) $NH_3$ និង $H_2O$



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

**ចម្លើយ**

ក)	HBr និង $H_2S$ ជាម៉ូលេគុលប៉ូលែ។ ដូចនេះ កម្លាំងរវាងម៉ូលេគុលទាំងពីរជាកម្លាំងឌីប៉ូល-ឌីប៉ូល ហើយវាក៏មានកម្លាំងឡុនដុនផងដែរ។

ខ)	$Cl_2$ និង $CBr_4$ ជាម៉ូលេគុលមិនប៉ូលែ។ ដូចនេះ កម្លាំងរវាងម៉ូលេគុលទាំងពីរជាកម្លាំងឡុនដុនតែមួយគត់។

គ)	$NH_3$ និង $H_2O$ ជាម៉ូលេគុលប៉ូលែ។ ដូចនេះ កម្លាំងរវាងម៉ូលេគុលទាំងពីរជាកម្លាំងឌីប៉ូល-ឌីប៉ូល។ ហើយវាក៏មានសម្ព័ន្ធអ៊ីដ្រូសែនផងដែរ។



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

# ជំពូកទី៣ អាស៊ីត-បាស

## មេរៀនទី១ ទ្រឹស្តីអាស៊ីត-បាស

### ១. លក្ខណៈអាស៊ីត-បាស

### ១.១ អាស៊ីត

**អាស៊ីត** គឺជាសមាសធាតុទាំងឡាយណា ដែលមានលក្ខណៈដូចជា៖ មានរសជាតិជូរ កាត់ ឬស៊ី និងមាន $pH < 7$។ អាស៊ីតជាអេឡិចត្រូលីត និងអាចប្រែពិណអង្គធាតុចង្អុលពណ៌។ អាស៊ីតមានប្រតិកម្ម ជាមួយបាសឲ្យ ផលជាអំបិលនិងទឹក ។

ឧទា. $HCl + NaOH \rightarrow NaCl + H_2O$

**អ៊ីដ្រូអាស៊ីត** ជាអាស៊ីតដែលផ្សំដោយ H និងធាតុមួយផ្សេងទៀតដែលមានកម្រិត អេឡិចត្រូអវិជ្ជមានខ្លាំង។

ឧទា. HF (អាស៊ីតភ្លុយអរីឌ្រិច) HCl (អាស៊ីតក្លរីឌ្រិច) $H_2S$ (អាស៊ីតស៊ុលភីឌ្រិច) ។

**អុកស៊ីអាស៊ីត** ជាអាស៊ីតដែលមានធាតុផ្សំ អ៊ីដ្រូសែន(H) អុកស៊ីសែន (O) និងធាតុទី៣ដែល ភាគច្រើនជាអលោហៈ ។

ឧទា. $HNO_3$ អាស៊ីតនីឌ្រិច $H_2SO_4$ អាស៊ីតស៊ុលផួរិច។

**អាស៊ីតបំបែកជាអ៊ីយ៉ុងអ៊ីដ្រូញ៉ូម ($H_3O^+$) ក្នុងទឹក**

$HCl (g) + H_2O (l) \rightarrow Cl^- (aq) + H_3O^+ (aq)$

$HF (g) + H_2O (l) \rightarrow F^- (aq) + H_3O^+ (aq)$

អាស៊ីត ជាសារធាតុគីមីសំខាន់ណាស់ក្នុងមន្ទីរពិសោធន៍ និងក្នុងឧស្សាហកម្ម ដូចជា៖

- អាស៊ីតស៊ុលផួរិច $H_2SO_4$ : ប្រើក្នុងឧស្សហកម្មផលិតលោហៈ ប្រេង ក្រដាស ល័ក្ខ សាប៊ូ...
- អាស៊ីតនីទ្រិច $HNO_3$ : ប្រើក្នុងឧស្សហកម្មផលិតប្លាស្ទិច ល័ក្ខ ឱសថ ជីគីមី គ្រឿងផ្ទុះ...
- អាស៊ីតផូស្វរិច $H_3PO_4$ : ប្រើក្នុងឧស្សហកម្មផលិតជីគីមី ចំណីសត្វ សាប៊ូ ...
-អាស៊ីតក្លរីឌ្រិច HCl : ក្នុងក្រពះ បន្សុទ្ធលោហៈ ភ្នាក់ងារសម្អាត ផលិតធាតុគីមី...
-អាស៊ីតអាសេទិច $CH_3COOH$ : ប្រើក្នុងឧស្សហកម្មផលិតប្លាស្ទិច ទឹកខ្មេះ អាហារ...

### លំហាត់គំរូ

ក- ចូរសរសេរសមីការតាងប្រតិកម្មរវាងអាស៊ីត $H_2SO_4$ និង$H_3PO_4$ ជាមួយ$Ca(OH)_2$ ។

ខ- គេមានសមាសធាតុអាស៊ីតបន្តបន្ទាប់នេះ $H_3PO_4$, $HClO_4$, HBr និង HI។ ចូរកំណត់អាស៊ីតទាំងនេះជាអ៊ីដ្រូអាស៊ីត និងអុកស៊ីអាស៊ីត ព្រមទាំងសរសេរសមីការអាស៊ីត HBr និង HI បំបែកជាអ៊ីយ៉ុងអ៊ីដ្រូញ៉ូម ($H_3O^+$)ក្នុងទឹក ។



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

**ចម្លើយ**

ក- សរសេរសមីការតាងប្រតិកម្ម

- $H_2SO_4$ (aq)+ $Ca(OH)_2$(aq) → $CaSO_4$(aq) + $H_2O$(l)
- $2H_3PO_4$(aq) +$3Ca(OH)_2$(aq) → $Ca_3(PO_4)_2$(aq) + $3H_2O$(l)

ខ- អ៊ីដ្រូអាស៊ីតមាន HBr និង HI

អុកស៊ីអាស៊ីតមាន $H_3PO_4$ និង$HClO_4$

សមីការបំបែកដោយទឹកនៃអាស៊ីត

HBr (g) + $H_2O$ (l) → $Br^-$(aq) + $H_3O^+$ (aq)

HI (g) + $H_2O$ (l) → $I^-$ (aq) + $H_3O^+$ (aq)

## ១.២-បាស

**បាស** គឺជាសមាសធាតុដែលមានលក្ខណៈដូចជា រសជាតិល្វីង កាត់ ឬស៊ី និងមាន pH>7 ។ បាសជា អេឡិចត្រូលីត និងអាចប្រែពណ៌អង្គធាតុចង្អុលពណ៌។ បាសមានប្រតិកម្មជាមួយអាស៊ីតឲ្យ ផលជាអំបិល និងទឹក ។

KOH + $HNO_3$ → $KNO_3$ + $H_2O$

**បាសបំបែកជាអ៊ីយ៉ុងអ៊ីដ្រុកស៊ីត($OH^-$) ក្នុងទឹក**

NaOH(s) → $Na^+$(aq) + $OH^-$ (aq)

$NH_3$ (g) + $H_2O$ (l) →$NH_4^+$ (aq) + $OH^-$ (aq)

បាស ជាសារធាតុគីមីសំខាន់ក្នុងមន្ទីរពិសោធន៍ និងក្នុងឧស្សាហកម្ម ដូចជា៖

- សូដ្យូមអ៊ីដ្រុកស៊ីត (NaOH) ត្រូវបានប្រើសម្រាប់ផលិតសាប៊ូ ក្រដាស និងសំយោគសារធាតុសរសៃដែលជារ៉ាយ៉ុង (rayon)។
- កាល់ស្យូមអ៊ីដ្រុកស៊ីត ($Ca(OH)_2$) ត្រូវបានប្រើសម្រាប់ផលិតម្សៅនៃសារធាតុបន្សុ។

### លំហាត់គំរូ

ចូរសរសេរសមីការតាងប្រតិកម្មរវាងអាស៊ីត KOH និង$Ca(OH)_2$ ជាមួយ $H_2SO_4$ ។

**ចម្លើយ**

2KOH(aq) + $H_2SO_4$(aq) → $K_2SO_4$(aq) + $2H_2O$(l)

$Ca(OH)_2$(aq) + $H_2SO_4$(aq) → $CaSO_4$(aq) + $2H_2O$(l)

## ២-អាស៊ីត-បាសតាមអារ៉េញ៉ូស

-*អាស៊ីត* ជាសមាសធាតុគីមីដែលបង្កើតអ៊ីយ៉ុងអ៊ីដ្រូសែន ( $H^+$ ) ក្នុងសូលុយស្យុងទឹក ។

ឧទា. HCl (g) → $H^+$ (aq) + $Cl^-$ (aq)

-*បាស* ជាសមាសធាតុគីមីដែលបង្កើតអ៊ីយ៉ុងអ៊ីដ្រុកស៊ីត( $OH^-$) ក្នុងសូលុយស្យុងទឹក ។

ឧទា. NaOH(s) → $Na^+$ (aq) + $OH^-$ (aq)

- សូលុយស្យុងអាស៊ីត ជាអេឡិចត្រូលីតដែលមានអ៊ីយ៉ុង $H^+$ ច្រើនជាងអ៊ីយ៉ុង $OH^-$ ។ ក្នុងសូលុយស្យុងទឹកអ៊ីយ៉ុង $H^+$ (ឬប្រូតុង)ចងសម្ព័ន្ធជាមួយម៉ូលេគុលទឹកបង្កើតជាអ៊ីយ៉ុង $H_3O^+$ ។

$H^+ (aq) + H_2O (l) \rightarrow H_3O^+ (aq)$

ដូច្នេះ អ៊ីយ៉ុងកម្មរបស់អាស៊ីតក្នុងទឹកគេអាចសរសេរៈ

ឧទា. $HCl(g) + H_2O(l) \rightarrow Cl^- (aq) + H_3O^+ (aq)$

$HNO_3 (l) + H_2O(l) \rightarrow NO_3^- (aq) + H_3O^+ (aq)$

-សូលុយស្យុងបាស ជាអេឡិចត្រូលីតដែលមានអ៊ីយ៉ុង $OH^-$ ច្រើនជាងអ៊ីយ៉ុង $H_3O^+$ ។

ឧទា. $NaOH(s) \rightarrow Na^+ (aq) + OH^- (aq)$

$NH_3 (g) + H_2O (l) \rightleftarrows NH_4^+ (aq) + OH^- (aq)$

**លំហាត់គំរូ**

ចូរជ្រើសរើសសមាសធាតុខាងក្រោមនេះ $NH_3$, $H_2SO_4$, HCl, NaOH និង$HNO_3$ ជាអាស៊ីត និងបាសអារ៉េញ៉ូស។

**ចម្លើយ**

អាស៊ីតអារ៉េញ៉ូសៈ $H_2SO_4$, $HNO_3$ និង HCl

បាសអារ៉េញ៉ូសៈ $NH_3$ និងNaOH

## ៣-អាស៊ីត-បាសតាមប្រុងស្តែត-ឡូរី

<u>**អាស៊ីត**</u> គឺជាប្រភេទគីមីទាំងឡាយណាដែលបោះបង់ប្រូតុង ($H^+$) ។

$HCl (g) + NH_3 (g) \rightarrow NH_4^+ (aq) + Cl^- (aq)$

HCl ជាអាស៊ីត ព្រោះវាបោះបង់ប្រូតុងឱ្យ $NH_3$ ។

<u>**បាស**</u> គឺជាប្រភេទគីមីទាំងឡាយណាដែលទទួលយកប្រូតុង ។

$NH_3 (g) + H_2O (l) \rightarrow NH_4^+ (aq) + OH^- (aq)$

$NH_3$ ជាបាស ព្រោះវាទទួលប្រូតុងពី $H_2O$ ។

**លំហាត់គំរូ**

ចូរកំណត់ប្រភេទគីមីទាំងនេះ $NH_3$, HCl, $NH_4^+$, HBr, NaOH និង $H_2SO_4$ ជាអាស៊ីត ឬបាសប្រុងស្តែត-ឡូរី។

**ចម្លើយ**

អាស៊ីតប្រុងស្តែត-ឡូរី HCl, HBr, $NH_4^+$ និង $H_2SO_4$

បាសប្រុងស្តែត-ឡូរី $NH_3$, NaOH

## ៤-អាស៊ីត-បាសតាមឡឺវីស

**អាស៊ីត** គឺជាប្រភេទគីមីទាំងឡាយណាដែលទទួលទ្វេតាអេឡិចត្រុង ដើម្បីបង្កើតសម្ព័ន្ធ



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

កូវ៉ាឡង់ ។



$H^+ (aq) + H_2O (l) \rightarrow H_3O^+ (aq)$

*អ៊ីយ៉ុង $H^+$ ជាអាស៊ីត*

**បាស** គឺជាប្រភេទគីមីទាំងឡាយណាដែលឲ្យទ្វេតាអេឡិចត្រុង ដើម្បីបង្កើតសម្ព័ន្ធកូវ៉ាឡង់ ។

ឧទាហរណ៍ ៖ $H^+(aq) + NH_3(aq) \rightarrow NH_4^+(aq)$



*$NH_3$ ជាបាស*

## ៥- ម៉ូណូប្រូទិច និងប៉ូលីប្រូទិចអាស៊ីត

*ម៉ូណូប្រូទិចអាស៊ីត* ជាអាស៊ីតដែលឲ្យប្រូតុងតែមួយក្នុងមួយម៉ូលេគុល ។

ឧទា. $HCl (aq) + H_2O (l) \rightarrow Cl^- (aq) + H_3O^+ (aq)$

$HNO_3 (aq) + H_2O (l) \rightarrow NO_3^- (aq) + H_3O^+ (aq)$

*ឌីប្រូទិចអាស៊ីត* ជាអាស៊ីតដែលឲ្យប្រូតុងពីរក្នុងមួយម៉ូលេគុល ។

ឧទា. $H_2SO_4 (aq) + H_2O (l) \rightarrow HSO_4^- (aq) + H_3O^+ (aq)$

$HSO_4^- (aq) + H_2O (l) \rightarrow SO_4^{2-} (aq) + H_3O^+ (aq)$

*ទ្រីប្រូទិចអាស៊ីត* ជាអាស៊ីតដែលឲ្យប្រូតុងបីក្នុងមួយម៉ូលេគុល ។

ឧទា. $H_3PO_4 (aq) + H_2O (l) \rightarrow H_2PO_4^- (aq) + H_3O^+ (aq)$

$H_2PO_4^- (aq) + H_2O (l) \rightarrow HPO_4^{2-} (aq) + H_3O^+ (aq)$

$HPO_4^{2-} (aq) + H_2O (l) \rightarrow PO_4^{3-} (aq) + H_3O^+ (aq)$

## ៦. កម្លាំងអាស៊ីត និងបាស

### ក. កម្លាំងអាស៊ីត

*អាស៊ីតខ្លាំង* ជាអាស៊ីតដែលបំបែកជាអ៊ីយ៉ុងអ៊ីដ្រូញ៉ូម ($H_3O^+$) សព្វក្នុងទឹក ។

$HCl (aq) + H_2O (l) \rightarrow Cl^- (aq) + H_3O^+ (aq)$

$HNO_3 (aq) + H_2O (l) \rightarrow NO_3^- (aq) + H_3O^+ (aq)$

$HClO_4 (aq) + H_2O (l) \rightarrow ClO_4^- (aq) + H_3O^+ (aq)$

$H_2SO_4 (aq) + 2H_2O (l) \rightarrow SO_4^{2-} (aq) + 2H_3O^+ (aq)$



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

***អាស៊ីតខ្សោយ*** ជាអាស៊ីតដែលបំបែកជាអ៊ីយ៉ុងអ៊ីដ្រូញ៉ូម ($H_3O^+$) មិនសព្វក្នុងទឹក ។

$HF (aq) + H_2O(l) \rightleftarrows F^- (aq) + H_3O^+ (aq)$

$HCN (aq) + H_2O(l) \rightleftarrows CN^- (aq) + H_3O^+ (aq)$

$CH_3COOH (aq) + H_2O(l) \rightleftarrows CH_3COO^- (aq) + H_3O^+ (aq)$

## ខ. កម្លាំងបាស

***បាសខ្លាំង*** ជាបាសដែលបំបែកជាអ៊ីយ៉ុងអ៊ីដ្រុងស៊ីត ($OH^-$) សព្វក្នុងទឹក ។

$KOH (s) \rightarrow K^+ (aq) + OH^- (aq)$

$NaOH (s) \rightarrow Na^+ (aq) + OH^- (aq)$

***បាសខ្សោយ*** ជាបាសដែលបំបែកជាអ៊ីយ៉ុងអ៊ីដ្រុកស៊ីត ($OH^-$) មិនសព្វក្នុងទឹក ។

$NH_3 (g) + H_2O(l) \rightleftarrows NH_4^+ (aq) + OH^- (aq)$

$C_6H_5NH_2 (aq) + H_2O(l) \rightleftarrows C_6H_5NH_3^+ (aq) + OH^- (aq)$

$CH_3COO^- (aq) + H_2O (l) \rightleftarrows CH_3COOH (aq) + OH^- (aq)$

## លំហាត់គំរូ

ចូរចាត់ថ្នាក់ប្រភេទគីមីបន្តបន្ទាប់នេះ $HCl$, $NaOH$, $NH_3$,$HC_2H_3O_2$, $HNO_3$, $C_6H_5NH_2$, $NaC_2H_5O_2$ និង$HClO_4$ ជាអាស៊ីតខ្លាំង អាស៊ីតខ្សោយ បាសខ្លាំង និងបាសខ្សោយ។

### ចម្លើយ

អាស៊ីតខ្លាំង: $HCl$, $HNO_3$, $HClO_4$

អាស៊ីតខ្សោយ: $HC_2H_3O_2$

បាសខ្លាំង: $NaOH$

បាសខ្សោយ: $NH_3$, $C_6H_5NH_2$



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

# មេរៀនទី ២ ប្រតិកម្មអាស៊ីត និងបាស

## ១. អាស៊ីត-បាសឆ្លាស់

ក.អាស៊ីត

$HCOOH + H_2O \rightleftarrows HCOO^- + H_3O^+$

$CH_3COOH + H_2O \rightleftarrows CH_3COO^- + H_3O^+$

$C_6H_5COOH + H_2O \rightleftarrows C_6H_5COO^- + H_3O^+$

អាស៊ីត បាសឆ្លាស់

ដូចនេះ បាសឆ្លាស់ គឺជាប្រភេទគីមីដែលនៅសល់ក្រោយពីអាស៊ីតប្រុងស្តែត-ឡូរីបោះបង់ប្រូតុង១ ។

ខ.បាស

$HCOO^- + H_2O \rightleftarrows HCOOH + OH^-$

$CH_3COO^- + H_2O \rightleftarrows CH_3COOH + OH^-$

$C_6H_5COO^- + H_2O \rightleftarrows C_6H_5COOH + OH^-$

បាស អាស៊ីតឆ្លាស់

ដូចនេះ អាស៊ីតឆ្លាស់ គឺជាប្រភេទគីមីដែលកើតឡើងពេលដែលបាសប្រុងស្តែត-ឡូរីចាប់យកប្រូតុង១។

លំហាត់គំរូ៖

ក- ចូរផ្តល់បាសឆ្លាស់របស់អាស៊ីតបន្តបន្ទាប់នេះ៖ $CH_2ClCOOH$, $HIO_4$, $H_3PO_4$, $NH_4^+$, $H_2S$។

ខ- ចូរផ្តល់អាស៊ីតឆ្លាស់របស់បាសបន្តបន្ទាប់នេះ៖ $NH_3$, $HSO_4^-$, $NO_2^-$, $CH_3CH_2COO^-$□

ចម្លើយ

ក- បាសឆ្លាស់របស់អាស៊ីត $CH_2ClCOOH$ គឺ $CH_2ClCOO^-$ , $HIO_4$ គឺ $IO_4^-$

$H_3PO_4$ គឺ $H_2PO_4^-$, $NH_4+$ គឺ $NH_3$ និង $H_2S$ គឺ $HS^-$ ។

ខ- អាស៊ីតឆ្លាស់របស់បាស $NH_3$ គឺ $NH_4^+$, $HSO_4^-$ គឺ $H_2SO_4$

$NO_2^-$ គឺ $HNO_2$ និង $CH_3CH_2COO^-$ គឺ$CH_3CH_2COOH$

## ២. គូអាស៊ីត-បាស

គូអាស៊ីត-បាស គឺជាគូនៃប្រភេទគីមីឆ្លាស់គ្នាដែលប្តូរប្រូតុងគ្នាទៅមក។ គូអាស៊ីត-បាស គេសរសេរ អាស៊ីត/បាស។

ឧទា- $NH_3(aq) + HF(aq) \rightleftarrows NH_4^+(aq) + F^-(aq)$

គេបានគូអាស៊ីត-បាស ២ គូ គឺ $NH_4^+/NH_3$ និង $HF/F^-$

**លំហាត់គំរូ**

ចូរកំណត់គូអាស៊ីតបាសនៃប្រតិកម្មនីមួយៗខាងក្រោមនេះ៖



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

a) $CH3COO^{-}$ + HCN ⇄ $CH_3COOH$ + $CN^{-}$

b) HClO + $CH_3NH_2$ ⇄ $CH_3NH_3^{+}$ + $ClO^{-}$

c) $CH_3CH_2COO^{-}$ + $H_2O$ ⇄ $CH_3CH_2COOH$ + $OH^{-}$

**ចម្លើយ**

a) គូអាស៊ីត-បាស ២ គូ គឺ $CH_3COOH/CH_3COO^{-}$ និង $HCN/CN^{-}$

b) គូអាស៊ីត-បាស ២ គូ គឺ $HClO/ClO^{-}$ និង $CH_3NH_3^{+}/CH_3NH_2$

c) គូអាស៊ីត-បាស ២ គូ គឺ $CH_3CH_2COOH/CH_3CH_2COO^{-}$ និង $H_2O/OH^{-}$

## ៣. ប្រតិកម្មអាស៊ីត-បាស

-អាស៊ីតខ្លាំង បាសខ្លាំង៖ $HCl(aq) + NaOH(aq) \rightarrow NaCl(aq) + H_2O(l)$

ល្បាយក្រោយប្រតិកម្មជាសូលុយស្យុងណឺត។

-អាស៊ីតខ្លាំង បាសខ្សោយ៖ $HCl(aq) + CH_3COONa(aq) \rightarrow NaCl(aq) + CH_3COOH(aq)$

ល្បាយក្រោយប្រតិកម្មជាសូលុយស្យុងអាស៊ីតខ្សោយ។

-អាស៊ីតខ្សោយ បាសខ្លាំង៖ $CH_3COOH(aq) + NaOH(aq) \rightarrow CH_3COONa(aq) + H_2O(l)$

ល្បាយក្រោយប្រតិកម្មជាសូលុយស្យុងបាសខ្សោយ។

**ចំណាំ៖** *ប្រតិកម្មទាំងបីប្រភេទខាងលើជាប្រតិកម្មសព្វ។*



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

# មេរៀនទី៣ សូលុយស្យុងទឹក និង pH

## ១-ស្វ័យអ៊ីយ៉ុងកម្ម ឬអូតូប្រូតូលីសនៃទឹក

-ម៉ូលេគុលទឹកមួយបោះបង់ប្រូតុងឲ្យទឹកមួយទៀត ហៅថា ស្វ័យអ៊ីយ៉ុងកម្មនៃទឹក ឬ អូតូប្រូតូលីសនៃទឹក។

$$H_2O\,(l) + H_2O\,(l) \rightleftarrows H_3O^+\,(aq) + OH^-\,(aq)$$

នៅសីតុណ្ហភាព25°C ទឹកសុទ្ធមាន pH =7 និងមានកំហាប់ $[H_3O^+] = [OH^-] = 10^{-7}mol.L^{-1}$

-ផលគុណរវាងកំហាប់អ៊ីយ៉ុង $H_3O^+$ និង $OH^-$ ហៅថាផលគុណអ៊ីយ៉ុងនៃទឹក (Ke ឬ Kw)។

$[H_3O^+] \times [OH^-] = Ke$ ផលគុណនេះមានតម្លៃថេរជានិច្ច

(ជាទំហំគ្មានខ្នាត ប្រែប្រួលតាមសីតុណ្ហភាព) ។

នៅសីតុណ្ហភាព 25°C ទឹកសុទ្ធមាន $K_e = [H_3O^+] \times [OH^-] = 10^{-14}$

*-មជ្ឈដ្ឋានសូលុយស្យុងមានបីគឺ*

$[H_3O^+] = [OH^-]$ ជាសូលុយស្យុងណឺត ( pH = 7 )

$[H_3O^+] > [OH^-]$ ជាសូលុយស្យុងអាស៊ីត ( pH < 7 )

$[H_3O^+] < [OH^-]$ ជាសូលុយស្យុងបាស ( pH > 7 )

**តម្លៃ Ke របស់ទឹកប្រែប្រួលតាមសីតុណ្ហភាព**

| សីតុ.(°C) | 0 | 10 | 20 | 25 | 30 | 40 | 50 | 100 |
|---|---|---|---|---|---|---|---|---|
| $K_e(10^{-14})$ | 0.114 | 0.293 | 0.681 | 1.008 | 1.471 | 2.916 | 5.476 | 51.3 |

## ២. មាត្រដ្ឋាន pH

**និយមន័យ pH៖**

- pH នៃសូលុយស្យុងរាវ ជាទំហំផ្ទុយនឹងឡូការីតគោលដប់នៃកំហាប់អ៊ីយ៉ុងអ៊ីដ្រូញ៉ូម $[H_3O^+]$ របស់សូលុយស្យុងនោះ ។

$$pH = -\log[H_3O^+] \Leftrightarrow [H_3O^+] = 10^{-pH}$$

- pOH នៃសូលុយស្យុងរាវ ជាទំហំផ្ទុយនឹងឡូការីតគោលដប់នៃកំហាប់អ៊ីយ៉ុងអ៊ីដ្រុកស៊ីត $[OH^-]$ របស់សូលុយស្យុងនោះ ។

$$pOH = -\log[OH^-] \Leftrightarrow [OH^-] = 10^{-pOH}$$

នៅសីតុណ្ហភាព25°C ទឹកសុទ្ធមាន $K_w = 10^{-14} \Leftrightarrow pK_w = -\log K_w = -\log 10^{-14} = 14$

$$pH + pOH = 14$$

<u>**សំគាល់**</u> សូលុយស្យុងណឺតនៅគ្រប់សីតុណ្ហភាពមាន $[H_3O^+] = [OH^-]$



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

**វង្វាស់ pH**

-កំណត់ pH ដោយប្រើក្រដាស pH ឬប្រើឧបករណ៍ pH ម៉ែត្រ ។

**លំហាត់គំរូ**

១- ចូរកំណត់ pH នៃអូតូប្រូតូលីសរបស់ទឹកនៅសីតុណ្ហភាព 30ºC

២- សូលុយស្យុងមួយមាន pH =7.52 ។ គណនា:

ក. កំហាប់អ៊ីយ៉ុងអ៊ីដ្រូញ៉ូម

ខ. កំហាប់អ៊ីយ៉ុងអ៊ីដ្រុកស៊ីត

គ. តើវាជាសូលុយស្យុងអាស៊ីត ឬ សូលុយស្យុងបាស?

**ចម្លើយ**

១- យើងមាន $K_e = [H_3O^+] \times [OH^-]$ ដោយនៅសីតុណ្ហភាព 30ºC របស់ទឹកគឺ $1.471 \times 10^{-14}$

ដូចនេះ $K_e = [H_3O^+] \times [OH^-] = 1.471 \times 10^{-14}$

ដោយវាជាអូតូប្រូតូលីសរបស់ទឹកយើងបាន $[H_3O^+] = [OH^-]$

$[H_3O^+]^2 = 1.471 \times 10^{-14}$ ⇨ $[H_3O^+] = 1.213\times10^{-7}$

$pH = -\log[H_3O^+] = 1.213\times10^{-7} = -\log[1.213\times10^{-7}] = -(\log 1.213 + \log 10^{-7}) = 6.92$

ដូច្នេះ pH នៃអូតូប្រូតូលីសរបស់ទឹកនៅសីតុណ្ហភាព 30ºC គឺ 6.92

២- ក. រកកំហាប់អ៊ីយ៉ុង $[H_3O^+]$

តាមសមីការ: $pH= -\log[H_3O^+] \Longrightarrow [H_3O^+] = 10^{-pH} = 10^{-7.52} = 10^{-8} \times 10^{0.48} = 3.0 \times 10^{-8}$ M

ខ. រកកំហាប់អ៊ីយ៉ុង$[OH^-]$

តាមសមីការ៖

$$k_w = [H_3O^+][OH^-] \Longrightarrow [OH^-] = \frac{k_w}{[H_3O^+]} = \frac{1.0 \times 10^{-14}}{3.0 \times 10^{-8}}$$

$$[OH^-] = 3.3 \times 10^{-7}\ M$$

គ. ដោយ pH = 7.25 ធំជាង pH = 7 មានន័យថា សូលុយស្យុងនេះ ជាសូលុយស្យុងបាស។



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

# មេរៀនទី៤ អត្រាកម្មអាស៊ីត-បាស

## ១. អត្រាកម្ម

-<u>ប្រតិកម្មបន្សាប</u> ជាប្រតិកម្មរវាងអ៊ីយ៉ុង $H_3O^+$ របស់អាស៊ីត និងអ៊ីយ៉ុង $OH^-$ របស់បាស ។

ឧទា- $NaOH (s) \rightarrow Na^+ (aq) + OH^- (aq)$

$HCl (g) + H_2O (l) \rightarrow H_3O^+ (aq) + Cl^- (aq)$

$H_3O^+ (aq) + OH^- (aq) \rightarrow 2H_2O$

*ប្រតិកម្មនេះ ជាប្រតិកម្មសព្វ*

**-អត្រាកម្ម(ឬអត្រាមាត្រ)អាស៊ីត-បាស** ជាលំនាំឬបច្ចេកទេសដែល គេប្រើនៅទីពិសោធន៍ដើម្បីកំណត់កំហាប់សូលុយស្យុងអាស៊ីត ឬ បាសមិនស្គាល់កំហាប់ ដោយប្រើសូលុយស្យុងបាស ឬ អាស៊ីតដែលស្គាល់កំហាប់ច្បាស់លាស់។ សូលុយស្យុងដែលគេស្គាល់កំហាប់ ហៅថា **សូលុយស្យុងស្តង់ដា** ។

## ២. ចំណុចសមមូលអាស៊ីត-បាស

ជាចំណុចដែលបរិមាណអាស៊ីត និងបរិមាណបាសប្រតិកម្មអស់ពីសូលុយស្យុង។

គេប្រើអង្គធាតុចង្អុលពណ៌ជាសញ្ញាប្រាប់ឲ្យដឹងថាចំណុចសមមូលកើតមាន ។

ទំនាក់ទំនងបរិមាណនៅចំណុចសមមូលអាស៊ីតបាស $C_a \times V_a = C_b \times V_b$

$C_a$ កំហាប់អាស៊ីត $C_b$ កំហាប់បាស

$V_a$ មាឌអាស៊ីត $V_b$ មាឌបាស

## ៣. ជម្រើសអង្គធាតុចង្អុលពណ៌

អង្គធាតុចង្អុលពណ៌ ជាសារធាតុសរីរាង្គដែលពណ៌របស់វាអាស្រ័យនឹងតម្លៃ pH ។

| អង្គធាតុចង្អុលពណ៌ | តំបន់ប្រែពណ៌ | ពណ៌អាស៊ីត | ពណ៌បាស |
|---|---|---|---|
| អេល្យ៉ង់ទីន (H) | 3.1 - 4.4 | ក្រហម | លឿងខ្ចី |
| ប្រូម៉ូទីម៉ូលខៀវ (BBT) | 6.0 - 7.6 | លឿង | ខៀវ |
| ផេណុលផ្តាលេអ៊ីន (PP) | 8.2 - 10.0 | គ្មានពណ៌ | កូឡាប |

-អត្រាកម្មអាស៊ីតខ្លាំង-បាសខ្លាំង ប្រើអង្គធាតុចង្អុលពណ៌ ប្រូម៉ូទីម៉ុលខៀវ ។

-អត្រាកម្មអាស៊ីតខ្សោយដោយបាសខ្លាំង ប្រើអង្គធាតុចង្អុលពណ៌ ផេណុលផ្តាលេអ៊ីន ។

-អត្រាកម្មបាសខ្សោយដោយអាស៊ីតខ្លាំង ប្រើអង្គធាតុចង្អុលពណ៌ អេល្យ៉ង់ទីន ។

**លំហាត់គំរូ**

សិស្សម្នាក់ធ្វើអត្រាកម្មសូលុយស្យុង HCl មិនស្គាល់កំហាប់ចំនួន 40.00mL ជាមួយនឹងសូលុយស្យុង NaOH កំហាប់ 0.5500M ។ មាឌសូលុយស្យុងបាសដែលត្រូវការចាំបាច់សម្រាប់ឲ្យដល់ចំណុចសមមូលមាន 24.64mL។ រកកំហាប់ជាម៉ូលរបស់សូលុយស្យុងHCl ។

**ចម្លើយ**



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

រកកំហាប់អ៊ីយ៉ុង $H_3O^+$ ក្នុងសូលុយស្យុង HCl

តាមសម្មតិកម្ម: $V(H_3O^+) = 40.00mL = 0.04L$

$V(OH^-) = 24.64mL = 0.02464L$

$C(OH^-) = 0.5500M$

តាមរូបមន្តនៅចំណុចសមមូល

$$C_AV_A = C_BV_B \Longrightarrow C_A = \frac{C_BV_B}{V_A}$$

$$= \frac{0.5500 \times 0.02464}{0.04}$$

$$C_A = 0.338\ M\ = 0.338\ mol/L$$

**ដូចនេះ** កំហាប់របស់សូលុយស្យុងអាស៊ីត HCl គឺស្មើ 0.338 M = 0.338 mol/L



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

# ជំពូកទី៤ លំនឹងគីមី
## មេរៀនទី១ ធម្មជាតិនៃលំនឹងគីមី

### ១. ប្រតិកម្មទៅមក

- ប្រតិកម្មចំហេះម៉ាញេស្យូមក្នុងខ្យល់បង្កើតបានម៉ាញេស្យូមអុកស៊ីត។

  $2Mg(s) + O_2(g) \rightarrow 2MgO(s)$

  ក្នុងប្រតិកម្មនេះ ម៉ាញេស្យូមអុកស៊ីតមិនអាចប្រតិកម្មជាមួយគ្នាបង្កើតជា ម៉ាញេស្យូម និង អុកស៊ីសែនវិញទេ។
- នៅពេលដុតកម្ដៅ បារត (II) អុកស៊ីត បំបែកជា បារត និងឧស្ម័នអុកស៊ីសែន។

  $2HgO(s) \rightarrow 2Hg(l) + O_2(g)$ (1)

  ក្នុងពេលប្រតិកម្មបំបែកកំពុងប្រព្រឹត្តទៅ បារត មានអំពើជាមួយ អុកស៊ីសែន ឲ្យផលជាបារត (II) អុកស៊ីតវិញ

  $2Hg(l) + O_2(g) \rightarrow 2HgO(s)$ (2)

  ប្រតិកម្មបែបនេះ ហៅថាប្រតិកម្មទៅមក ដែលអាចសរសេរជា

  $2HgO(s) \underset{(2)}{\overset{(1)}{\rightleftharpoons}} 2Hg(l) + O_2(g)$

- ប្រតិកម្មទៅមកគឺជាប្រតិកម្មដែលក្នុងនោះអង្គធាតុកកើត(ផលិតផល) អាចមានប្រតិកម្មជាមួយគ្នាបង្កើតអង្គធាតុប្រតិករវិញ។

### ២. លំនឹងគីមី

ប្រតិកម្មគីមីជាច្រើន ជាប្រតិកម្មទៅមកនៅក្រោមលក្ខខណ្ឌសីតុណ្ហភាព និងកំហាប់ប្រក្រតី។ ប្រតិកម្មទាំងនោះទៅដល់ស្ថានភាពលំនឹង បើគ្មានសារធាតុណាមួយត្រូវបានរំដោះចេញពីប្រព័ន្ធគីមី។

- ករណីខ្លះ ប្រតិកម្មតាមទិសបណ្ដោយប្រព្រឹត្តទៅស្ទើរទាំងស្រុង ទើបមានប្រតិកម្មតាមទិសច្រាសកើតឡើង។ ដូចនេះ នៅពេលមានលំនឹងគីមី កំហាប់អង្គធាតុកកើតធំជាងអង្គធាតុប្រតិករ។ គេថាលំនឹងទោរទៅខាងស្ដាំ ជាប្រតិកម្មនាំមុខ។

  ឧទា. $2SO_2(g) + O_2(g) \rightleftharpoons 2SO_3(g)$
- ករណីខ្លះ ប្រតិកម្មតាមទិសបណ្ដោយប្រព្រឹត្តទៅដោយលំបាក និងប្រតិកម្មតាមទិសច្រាសប្រព្រឹត្តទៅងាយស្រួល។ ដូចនេះ នៅពេលមានលំនឹងគីមី កំហាប់អង្គធាតុប្រតិករធំជាងអង្គធាតុកកើត។ គេថា លំនឹងទោរទៅខាងឆ្វេង ជាប្រតិកម្មនាំមុខ។

  ឧទា. $H_2CO_3(aq) + H_2O(l) \rightleftharpoons H_3O^+(aq) + HCO_3^-(aq)$



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

## ៣. កន្សោមថេរលំនឹង

ឧបមាថា គេមានអង្គធាតុ A និងB មានប្រតិកម្មនឹងគ្នា បង្កើតបានជាអង្គធាតុ C និងD ហើយអង្គធាតុ C និងD មានប្រតិកម្មជាមួយគ្នាបង្កើតបានជាអង្គធាតុ Aនិង Bវិញ។ នៅពេលលំនឹងគីមី គេបានសមីការតុល្យការ៖

$$a\,A + b\,B \rightleftarrows c\,C + d\,D$$

គេបានកន្សោមថេរលំនឹង K ៖

$$K=\frac{[C]^c\times[D]^d}{[A]^a\times[B]^b}$$

ថេរ K ឬថេរលំនឹង K ជាទំហំគ្មានខ្នាត ឯកំហាប់ប្រភេទគីមី គិតជា $mol.L^{-1}$។

ថេរ K មិនអាស្រ័យនឹងកំហាប់ប្រភេទគីមីទេ តែអាស្រ័យនឹងសីតុណ្ហភាព។

ឧទា. ប្រតិកម្មរវាង $H_2$ និង $I_2$ នៅលក្ខខណ្ឌកំណត់មួយ តាងដោយសមីការតុល្យការ៖

$$H_2(g) + I_2(g) \rightleftarrows 2HI(g)$$

កន្សោមថេរលំនឹងគីមី គឺ៖ $K=\dfrac{[HI]^2}{[H_2]\times[I_2]}$

**លំហាត់គំរូទី១**

គេមានប្រតិកម្មមួយស្ថិតក្នុងភាពលំនឹង៖

$$2SO_2(g) + O_2(g) \rightleftarrows 2SO_3(g)$$

តើមួយណាជាកន្សោមថេរលំនឹងត្រឹមត្រូវនៃប្រតិកម្មខាងលើ រវាង

$K=\dfrac{[SO_3]^2}{[SO_2]^2\times[O_2]}$ និង $K=\dfrac{[SO_2]^2\times[O_2]}{[SO_3]^2}$

**ចម្លើយ**

កន្សោមថេរលំនឹងនៃប្រតិកម្ម $2SO_2(g) + O_2(g) \rightleftarrows 2SO_3(g)$គឺ៖

$$K=\frac{[SO_3]^2}{[SO_2]^2\times[O_2]}$$

**លំហាត់គំរូទី២**

ប្រតិកម្មនៃការការបង្កើតបានជាអាម៉ូញាក់អាចសរសេរបានតាមច្រើនវិធី៖

A. $N_2(g) + 3H_2(g) \rightleftarrows 2NH_3(g)$

B. $\frac{1}{2} N_2(g) + 3/2\, H_2(g) \rightleftarrows NH_3(g)$

C. $1/3\, N_2(g) + H_2(g) \rightleftarrows 2/3\, NH_3(g)$

ចូរសរសេរថេរលំនឹងនៃសមីការតាងប្រតិកម្មនីមួយៗ



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

## ចម្លើយ

កន្សោមថេរលំនឹង

A. $K = \frac{[NH_3]^2}{[N_2][H_2]^3}$

B. $K = \frac{[NH_3]}{[N_2]^{1/2}[H_2]^{3/2}}$

C. $K = \frac{[NH_3]^{2/3}}{[N_2]^{1/3}[H_2]}$

## លំហាត់គំរូទី៣

ល្បាយនៃ$H_2$ 0.500 mol និង $I_2$ 0.500 mol ត្រូវបានដាក់ក្នុងកែវដែកថែបដែល គ្មានច្រែះចំនុះ 1L នៅសីតុណ្ហភាព 430$^0$C ។ ថេរលំនឹងសម្រាប់ប្រតិកម្មគឺ 54.3

$$H_2(g) + I_2(g) \rightleftharpoons 2HI(g)$$

ចូរគណនាកំហាប់នៃ$H_2$, $I_2$ និង HI នៅពេលលំនឹង។

## ចម្លើយ

*ជំហានទី១*

សមីការតុល្យការ

| | $H_2(g)$ + | $I_2(g)$ $\rightleftharpoons$ | $2HI(g)$ |
|---|---|---|---|
| កំហាប់ដើម(M): | 0.500 | 0.500 | 0.00 |
| កំហាប់ប្រែប្រួលដោយប្រតិកម្ម(M): | -x | -x | + 2x |
| កំហាប់ពេលលំនឹង(M): | (0.500-x) | (0.500-x) | 2x |

*ជំហានទី២*

កន្សោមថេរលំនឹងគឺ

$$K = \frac{[HI]^2}{[H_2]\,[I_2]}$$

ដោយជំនួសកំហាប់ចូលយើងបាន

$$54.3 = \frac{(2x)^2}{(0.500-x)(0.500-x)} = \frac{(2x)^2}{(0.500-x)^2}$$

បំពាក់រ៉ាស៊ីនការ៉េលើអង្គទាំងសងខាងយើងបាន $7.37 = 2x / (0.500-x) \Rightarrow x = 0.393$ M

*ជំហានទី៣*

នៅលំនឹង កំហាប់របស់ប្រភេទគីមីគឺ $[H_2] = (0.500 – 0.393)$ M = 0.107 M



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

$[I_2] = (0.500 – 0.393)\ M = 0.107\ M$

$[HI] = (2 \times 0.393)\ M = 0.786\ M$

ដូចនេះ កំហាប់នៅពេលមានលំនឹងនៃ $[H_2] = 0.107\ M$

$[I_2] = 0.107\ M$

$[HI] = 0.786\ M$



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

# មេរៀនទី២ ការរំកិលលំនឹង

## ១. ព្យាករណ៍នៃរំកិលលំនឹង

### គោលការណ៍ឡឺសាតឺលីយេ

ប្រព័ន្ធមួយកំពុងមានលំនឹងរងនូវភាពតានតឹង លំនឹងនោះរំកិលតាមទិសដៅដែលមានទំនោររំដោះភាពតានតឹង ។ កត្តាដែលនាំឲ្យមានភាពតានតឹង(រំខាន) ដល់លំនឹងគីមី គឺ*សម្ពាធ កំហាប់ និងសីតុណ្ហភាព* ។

### ១.១ បម្រែបម្រួលសម្ពាធ

- ការប្រែប្រួលសម្ពាធក្នុងប្រព័ន្ធប្រតិកម្ម មានឥទ្ធិពលទៅលើលំនឹងនៃប្រព័ន្ធដែលមានភាពរូបជាឧស្ម័ន និងចំនួនម៉ូលេគុល (ឬចំនួនម៉ូល) សរុបនៃអង្គធាតុប្រតិករខុសគ្នាពីចំនួនម៉ូលេគុល(ឬចំនួនម៉ូល ) សរុបនៃអង្គធាតុកកើត ។

- ពេលគេបង្កើនសម្ពាធទៅលើប្រព័ន្ធគីមី លំនឹងរំកិលពីផ្នែកដែលមានចំនួនម៉ូលសរុបច្រើនជាង ទៅរកផ្នែកដែលមានចំនួនម៉ូលតិចជាង ("ផ្នែក" គឺអង្គធាតុប្រតិករ ឬអង្គធាតុកកើត)។

ឧទា- $N_2\,(g) + 3H_2\,(g) \underset{(2)}{\overset{(1)}{\rightleftharpoons}} 2NH_3\,(g)$

1 mol 3 mol 2 mol

យើងឃើញថា ចំនួនម៉ូលសរុបនៃអង្គធាតុប្រតិករមាន 4 mol និងចំនួនម៉ូលសរុបនៃអង្គធាតុកកើតមាន 2 mol។ ដូច្នេះ ការបង្កើនសម្ពាធ នាំឲ្យលំនឹងរំកិលតាមទិសដៅ(1)។

### ១.២ បម្រែបម្រួលកំហាប់

ការបង្កើនកំហាប់ប្រតិករ ក៏បង្កើនភាពតានតឹងដែរ ។ ប្រព័ន្ធលំនឹងគីមីមួយតាងដោយសមីការតុល្យការ ៖ $A + B \underset{(2)}{\overset{(1)}{\rightleftharpoons}} C + D$

ដូច្នេះ កាលណាបន្ថែមអង្គធាតុ A ឬ B នាំឲ្យលំនឹងរំកិលតាមទិសដៅ(1)។ការប្រែប្រួលកំហាប់ពុំមានប៉ះពាល់ដល់តម្លៃថេរលំនឹង K ទេ ។

កំហាប់អង្គធាតុរឹងសុទ្ធនិងកំហាប់អង្គធាតុរាវសុទ្ធពុំប្រែប្រួលទេតាមសន្មត គេមិនសរសេរកំហាប់អង្គធាតុរឹងនិងអង្គធាតុរាវនៅក្នុងកន្សោមថេរលំនឹងទេ។

ឧទា. $CaCO_3(s) \underset{(2)}{\overset{(1)}{\rightleftharpoons}} CaO(s) + CO_2(g) \quad K = [CO_2]$

$$CH_3COOH(aq) + H_2O(l) \underset{(2)}{\overset{(1)}{\rightleftharpoons}} CH_3COO^-(aq) + H_3O^+(aq) \quad K = \frac{[CH_3COO^-]\times[H_3O^+]}{[CH_3COOH]}$$

$$H_2O(l) + H_2O(l) \underset{(2)}{\overset{(1)}{\rightleftharpoons}} H_3O^+(aq) + OH^-(aq) \quad K = [H_3O^+]\times[OH^-] = K_e$$

### ១.៣ បម្រែបម្រួលសីតុណ្ហភាព

កាលណាសីតុណ្ហភាពកើន នាំឲ្យលំនឹងគីមីរំកិលតាមទិសដៅប្រតិកម្មស្រូបកម្ដៅ ។



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

ឧទា. (១) ប្រតិកម្មសំយោគអាម៉ូញាក់

$$N_2(g) + 3H_2(g) \underset{(2)}{\overset{(1)}{\rightleftharpoons}} 2NH_3(g) + 92kJ$$

ជាប្រតិកម្មបញ្ចេញកម្តៅ ។

ដូចនេះ កាលណាសីតុណ្ហភាពកើន នាំឲ្យលំនឹងគីមីរំកិលតាមទិសដៅ(2) ។

(២) ការផលិតឪអាសូតតេត្រាអុកស៊ីត

$$2NO_2(g) \underset{(2)}{\overset{(1)}{\rightleftharpoons}} N_2O_4(g) + \text{កម្តៅ}$$

ជាប្រតិកម្មបញ្ចេញកម្តៅ ។

ដូចនេះ កាលណាសីតុណ្ហភាពថយចុះ លំនឹងគីមីរំកិលតាមទិសដៅ(1) ។

*កាលណាសីតុណ្ហភាពប្រែប្រួល នាំឲ្យថេរលំនឹង K ប្រែប្រួលដែរ ។*

**លំហាត់គំរូ**

(1) ប្រតិកម្មខាងក្រោមស្ថិតក្នុងភាពលំនឹង៖

$$2CO(g) + O_2(g) \underset{(2)}{\overset{(1)}{\rightleftharpoons}} 2CO_2(g) + \text{កម្តៅ}$$

ចូរពន្យល់ពីការរំកិលលំនឹង ពេល៖

ក) សីតុណ្ហភាពនៃប្រព័ន្ធកើនឡើង

ខ) បង្រួមមាឌកែវប្រតិកម្ម

គ) បន្ថែមឧស្ម័ន $CO_2$ ចូលក្នុងប្រព័ន្ធប្រតិកម្មនៅសម្ពាធថេរ

ឃ) បន្ថែមឧស្ម័ន He ចូលក្នុងប្រព័ន្ធប្រតិកម្មនៅមាឌថេរ

**ចម្លើយ**

ក) ករណីសីតុណ្ហភាពនៃប្រព័ន្ធកើនឡើង

ដោយប្រតិកម្មតាមទិសដៅ(1) ជាប្រតិកម្មបញ្ចេញកម្តៅ យើងអាចនិយាយបានថា ប្រតិកម្មតាមទិសដៅ (2) ជាប្រតិកម្មស្រូបកម្តៅ។ ដូចនេះ ប្រសិនបើសីតុណ្ហភាពនៃប្រព័ន្ធកើនឡើង នោះលំនឹងនៃប្រតិកម្មរំកិលតាមទិសដៅ (2)។

ខ) ករណីបង្រួមមាឌកែវប្រតិកម្ម

ការបង្រួមមាឌកែវ ធ្វើឲ្យសម្ពាធក្នុងកែវកើនឡើង មានន័យថាបង្កើនសម្ពាធនៃប្រព័ន្ធប្រតិកម្ម។ ដោយប្រភេទគីមីសុទ្ធតែជាឧស្ម័ន នោះលំនឹងរំកិលទៅរកផ្នែកដែលមានចំនួនម៉ូលតិចជាង គឺលំនឹងរំកិលតាមទិសដៅ (1)។

គ) ករណីបន្ថែមឧស្ម័ន $CO_2$ ចូលក្នុងប្រព័ន្ធប្រតិកម្មនៅសម្ពាធថេរ

ការបន្ថែមឧស្ម័ន $CO_2$ ចូលក្នុងប្រព័ន្ធប្រតិកម្ម មានន័យថា បង្កើនកំហាប់ $CO_2$។ នៅពេលកំហាប់ $CO_2$ កើន នោះលំនឹងរំកិលតាមទិសដៅ (2) ។



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

ឃ) បន្ថែមឧស្ម័ន He ចូលក្នុងប្រព័ន្ធប្រតិកម្មនៅមាឌថេរ

ការបន្ថែមឧស្ម័ន He ចូលក្នុងប្រព័ន្ធប្រតិកម្ម ធ្វើឲ្យសម្ពាធដោយផ្នែកនៃឧស្ម័នប្រតិកម្មមិនប្រែប្រួលទេ។ ដូចនេះមិនមានការរំកិលលំនឹងទៅរកលំនឹងថ្មីទេ។

## ២. ប្រតិកម្មឈានទៅរកសព្វ

អ៊ីយ៉ុងខ្លះ ចូលរួមប្រតិកម្មជាមួយគ្នា ឲ្យផលជាឧស្ម័ន ឬកករ ឬអង្គធាតុបំបែកជាអ៊ីយ៉ុងបានតិច។ ប្រតិកម្មបែបនេះនឹងឈានទៅរកសព្វ ។

### ២.១ ប្រតិកម្មកំណាឧស្ម័ន

អ៊ីយ៉ុងខ្លះ ចូលធ្វើប្រតិកម្មជាមួយគ្នា ឲ្យផលជាសារធាតុមិនស៊ប់(មិនមានស្ថិរភាព)ហើយវាបំបែកជាឧស្ម័នភ្លាម ។

ឧទា. $2H_3O^+ (aq) + CO_3^{2-} (aq) \underset{(2)}{\overset{(1)}{\rightleftharpoons}} H_2CO_3 (aq) + 2H_2O (l)$

$H_2CO_3(aq) \underset{(2)}{\overset{(1)}{\rightleftharpoons}} 2H_2O (l) + CO_2(g)$

ប្រតិកម្មនេះ ជាប្រតិកម្មឈានទៅរកសព្វ ព្រោះផលិតផលកកើតជាឧស្ម័ន$CO_2$ ។

### ២.២. ប្រតិកម្មឲ្យផលជាកករ

បើគេលាយសូលុយស្យុង $AgNO_3$ និង NaCl គេទទួលបានកករ AgCl ។

$AgNO_3 (aq) + NaCl(aq) \underset{(2)}{\overset{(1)}{\rightleftharpoons}} AgCl(s) + NaCl(aq)$

$Ag^+ (aq) + Cl^- (aq) \underset{(2)}{\overset{(1)}{\rightleftharpoons}} AgCl (s)$

ប្រតិកម្មនេះ ជាប្រតិកម្មឈានទៅរកសព្វ ព្រោះផលិតផលកកើតជាកករ AgCl ។

### ២.៣ ប្រតិកម្មផលជាសារធាតុបំបែកអ៊ីយ៉ុងបានតិច

បើគេលាយសូលុយស្យុង HCl និង NaOH គេទទួលបានទឹក ។

$HCl(aq) + NaOH(aq) \underset{(2)}{\overset{(1)}{\rightleftharpoons}} NaCl(aq) + H_2O(l)$

ឬ $H_3O^+ (aq) + OH^- (aq) \underset{(2)}{\overset{(1)}{\rightleftharpoons}} 2H_2O (l)$

ប្រតិកម្មនេះ ជាប្រតិកម្មឈានទៅរកសព្វ ព្រោះផលិតផលកកើតជាសារធាតុបំបែកជាអ៊ីយ៉ុងបានតិច ។

## ៣. ផលអ៊ីយ៉ុងរួម

បើគេបន្ថែមអ៊ីយ៉ុងណាមួយចូលទៅក្នុងសូលុយស្យុងមួយទៀតដែលមានវត្តមានអ៊ីយ៉ុងនោះដែរ និងធ្វើឱ្យមានការប្រែប្រួលដល់លំនឹង ដូចជាបណ្តាលឱ្យកើតជាកករ ឬឧស្ម័ននៃសមាសធាតុប្រតិករវិញ បាតុភូតនេះ គេហៅថា ផលអ៊ីយ៉ុងរួម។



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

### ៣.១ ផលអ៊ីយ៉ុងរួមឲ្យជាកករ

គេអាចរំកិលលំនឹងនៃប្រតិកម្មណាមួយទៅតាមទិសដៅដែលចង់បានតាមគោលការណ៍ឡឺសាតឺលីយេ ។ គេមានសូលុយស្យុងសូដ្យូមក្លរួឆ្អែត ដែលមានសមីការលំនឹង៖

$$NaCl (s) \underset{(2)}{\overset{(1)}{\rightleftharpoons}} Na^{+} (aq) + Cl^{-}(aq)$$

បើគេបន្ថែមអ៊ីដ្រូសែនក្លរួ (HCl) ទៅក្នុងសូលុយស្យុងខាងលើ នាំឲ្យអ៊ីយ៉ុងក្លរួ($Cl^-$) មានអំពើជាមួយអ៊ីយ៉ុងសូដ្យូម ($Na^+$) ឲ្យផលជាកករសូដ្យូមក្លរួ (NaCl) វិញ ។

### ៣.២ ផលអ៊ីយ៉ុងរួមបន្ថយកំរិតអ៊ីយ៉ុងកម្ម

អាស៊ីតអាសេទិចជាអាស៊ីតខ្សោយ $CH_3COOH$ នៅកំហាប់ 0.1M វាអាចចបំបែកជាអ៊ីយ៉ុង $H_3O^+$ បានតែ 1.3% ប៉ុណ្ណោះ ។

$$CH_3COOH(aq) + H_2O(l) \rightleftharpoons CH_3COO^{-}(aq) + H_3O^{+}(aq)$$

បើគេបន្ថែម $CH_3COONa$ បន្តិចទៅក្នុងសូលុយស្យុងខាងលើ នាំឲ្យអ៊ីយ៉ុង $CH_3COO^-$ បានពី $CH_3COONa$ មានអំពើជាមួយអ៊ីយ៉ុង $H_3O^+$ ក្នុងសូលុយស្យុង $CH_3COOH$ បង្កើតជា $CH_3COOH$ វិញ។

#### លំហាត់គំរូ

ប្រតិកម្មខាងក្រោមនេះប្រព្រឹត្តទៅនៅសីតុណ្ហភាព 400ºC ៖

$$H_2 (g) + I_2 (g) \underset{(2)}{\overset{(1)}{\rightleftharpoons}} 2HI (g) \qquad K = 50,0$$

គេយក 0,0800 mol នៃអ៊ីដ្រូសែន និង 0,0800 mol នៃអ៊ីយ៉ូត ទៅដាក់ក្នុងកែវចំណុះ1.0L ហើយបិទជិត និងទុកឲ្យប្រព្រ័ន្ធមានលំនឹង ។ ចូរកំណត់រកកំហាប់អ៊ីយ៉ូតនៅពេលលំនឹង ។

**ចម្លើយ**

កំណត់រកកំហាប់អ៊ីយ៉ូតនៅពេលលំនឹង

| $H_2 (g)$ | + $I_2 (g)$ | $\underset{(2)}{\overset{(1)}{\rightleftharpoons}}$ | $2HI (g)$ | $K = 50,0$ |
|---|---|---|---|---|
| 0.08M | 0.08M | | 0 | |
| x | x | | 2x | |
| 0.08-x | 0.08-x | | 2x | |

វិធីទីមួយ $K = \frac{[HI]^2}{[H_2]\times[I_2]} = \frac{(2x)^2}{(0,08-x)^2} = \frac{(2x)^2}{(0,08)^2} = \frac{2x}{0,08} = \sqrt{50}$

$2x = 0,08\times7,07=0.5656$

$x = 0.2828M$

ដូចនេះ $[I_2] = 0.08 – 0.28 = – \underline{0.2M}$ (មិនយក)

វិធីទីពីរ $K = \frac{[HI]^2}{[H_2]\times[I_2]} = \frac{(2x)^2}{(0,08-x)^2} = 50$

$$= \frac{2x}{0.08 - x} = \sqrt{50} = 7.07$$

2x = 0.5656 – 7.07x

2x + 7.07x = 0.5656

$$x = \frac{0.5656}{9.07} = 0.06M$$

ដូចនេះ $[I_2] = 0.08 - 0.06 = \underline{0.02M}$ (យក)

---



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

# មេរៀនទី៣ លំនឹងនៃអាស៊ីត បាស និងអំបិល

## ១-ថេរអ៊ីយ៉ុងកម្មនៃអាស៊ីតខ្សោយ

- អាស៊ីតអាសេទិច ជាអាស៊ីតខ្សោយ វាបំបែកក្នុងទឹកតាមសមីការតុល្យការ៖

$$CH_3COOH(aq) + H_2O(l) \underset{(2)}{\overset{(1)}{\rightleftharpoons}} CH_3COO^-(aq) + H_3O^+(aq)$$

កន្សោមថេរលំនឹងសរសេរ $K_a = \frac{[CH_3COO^-]\times[H_3O^+]}{[CH_3COOH]}$

$K_a$ ហៅថា ថេរអ៊ីយ៉ុងកម្មនៃអាស៊ីត ឬថេរអាស៊ីត។

**លំហាត់គំរូ**

សូលុយស្យុងអាស៊ីត HA មួយនៅកំហាប់ 0.1M មាន pH = 2.2 ។

ចូរកំណត់រកថេរអ៊ីយ៉ុងកម្មនៃអាស៊ីត ។ គេឲ្យ: $10^{0,8} = 6.3$ ។

**ចម្លើយ**

កំហាប់ $H_3O^+$ ពេលលំនឹង

$$[H_3O^+] = 10^{-pH} = 10^{-2,2} = 10^{0.8}\times10^{-3} = 6.3\times10^{-3}M$$
$$= 0.0063M$$

| | | | | | | |
|---|---|---|---|---|---|---|
| សមីការតុល្យការ | HA(aq) | + | $H_2O$(g) | $\underset{(2)}{\overset{(1)}{\rightleftharpoons}}$ | $A^-$(aq) + | $H_3O^+$ (aq) |
| កំហាប់ដើម | 0,1M | | | | 0 | 0 |
| កំហាប់ប្រែប្រួល | 0,0063M | | | | 0.0063M | 0.0063M |
| កំហាប់ពេលលំនឹង | 0.1M – 0,0063M | | | | 0.0063M | 0.0063M |

$$K_a = \frac{[A^-]\times[H_3O^+]}{[HA]} = \frac{0.0063\times0.0063}{(0.1-0.0063)} = \frac{(0.0063)^2}{0.0937} = 4.23\times10^{-4}$$

## ២. ថេរអ៊ីយ៉ុងកម្មនៃទឹក

ទឹកមានអំពើជាមួយគ្នាតាមសមីការតុល្យការ:

$$H_2O\ (l) + H_2O\ (l) \underset{(2)}{\overset{(1)}{\rightleftharpoons}} H_3O^+\ (aq) + OH^-\ (aq)$$

ប្រតិកម្មនេះហៅថា ប្រតិកម្មស្វ័យអ៊ីយ៉ុងកម្មឬអូតូប្រូតូលីសនៃទឹក ។ កំហាប់ $H_3O^+$ និង $OH^-$ តូចណាស់។

កន្សោមថេរអ៊ីយ៉ុងកម្មនៃទឹកសរសេរ ៖

$$K_e = [H_3O^+]\times[OH^-] = K_w = 10^{-14}$$ នៅ 25°C ។

## ៣. អ៊ីយ៉ុងកម្មនៃអំបិល

អំបិលជាផលិតផលនៃប្រតិកម្មបន្សាបរវាងអាស៊ីត និងបាស ។ពេលអំបិលរលាយក្នុងទឹក វាបំបែកជា អ៊ីយ៉ុង(កាចុង និងអាញ៉ុង) ។ អំបិលខ្លះរលាយក្នុងទឹក ឲ្យជាសូលុយស្យុងណឺតមាន



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

pH = 7 ។ អំបិល $Na_2CO_3$ រលាយក្នុងទឹក ឲ្យជាសូលុយស្យុងបាសមាន pH ធំជាង 7 ។ អំបិល $NH_4Cl$ រលាយក្នុងទឹកឲ្យជាសូលុយស្យុងបាសមាន pH តូចជាង 7។

អ៊ីយ៉ុងដែលបានពីអាស៊ីតខ្សោយ ឬបាសខ្សោយមានអំពើជាមួយទឹកឲ្យជាសូលុយស្យុងមាន pH ធំជាង ឬតូចជាង 7 ។

### ៣.១ អ៊ីដ្រូលីសនៃអាញ៉ុង

អ៊ីដ្រូលីសនៃអាញ៉ុងជាអំពើរវាងអ៊ីយ៉ុងអវិជ្ជមានជាមួយទឹក ឲ្យផលជាសូលុយស្យុងបាស។ តាង HA ជាអាស៊ីតខ្សោយដែលមានអំពើជាមួយទឹក ឲ្យផលជាអាញ៉ុង $A^-$ និងអ៊ីយ៉ុង $H_3O^+$ តាមសមីការលំនឹង ៖ $HA\,(aq) + H_2O\,(l) \underset{(2)}{\overset{(1)}{\rightleftharpoons}} A^-\,(aq) + H_3O^+\,(aq)$

អាញ៉ុង $A^-$ ជាបាសឆ្លាស់នៃអាស៊ីតខ្សោយ វាទទួលប្រូតុងពីទឹក ឲ្យជាអាស៊ីតនិងអ៊ីយ៉ុង $OH^-$ ។ តាមសមីការលំនឹង ៖ $A^-\,(aq) + H_2O\,(l) \underset{(2)}{\overset{(1)}{\rightleftharpoons}} HA\,(aq) + OH^-\,(aq)$

អ៊ីដ្រូលីសនៃអាញ៉ុង $A^-$ ធ្វើឲ្យកំហាប់ $OH^-$ កើនឡើងនៅក្នុងសូលុយស្យុងហេតុនេះហើយបានជាសូលុយស្យុងទទួលបានជាសូលុយស្យុងបាស។

ដូច្នេះ អាស៊ីត HA កាន់តែខ្សោយ បាសឆ្លាស់ $A^-$ កាន់តែខ្លាំង ។

ឧទា. សូដ្យូមកាបូណាត $Na_2CO_3$ ជាបាស

$Na_2CO_3\,(s) \longrightarrow 2Na^+\,(aq) + CO_3^{2-}\,(aq)$

$Na^+\,(aq) + H_2O \longrightarrow$ គ្មាន

$CO_3^{2-}\,(aq) + H_2O \longrightarrow HCO_3^-\,(g) + OH^-\,(aq)$

អ៊ីដ្រូលីស $CO_3^{2-}$ ដែលបានពី $NaCO_3$ បង្កើតបាន $OH^-$ ក្នុងសូលុស្យុង។

ដូចនេះសូលុយស្យុង$Na_2CO_3$ ជាបាស ។

### ៣.២ អ៊ីដ្រូលីសនៃកាចុង

អ៊ីដ្រូលីសនៃកាចុងជាអំពើរវាងអ៊ីយ៉ុងវិជ្ជមានជាមួយទឹក ឲ្យផលជាសូលុយស្យុងអាស៊ីត។ តាង B ជាបាសខ្សោយដែលមានអំពើជាមួយទឹកឲ្យផលជាអាញ៉ុង $BH^+$ និងអ៊ីយ៉ុង$OH^-$

តាមសមីការលំនឹង: $B\,(aq) + H_2O\,(l) \underset{(2)}{\overset{(1)}{\rightleftharpoons}} BH^+\,(aq) + OH^-\,(aq)$

កាចុង $BH^+$ ជាអាស៊ីតឆ្លាស់នៃបាសខ្សោយ វាបោះបង់ប្រូតុងឲ្យទឹក ឲ្យជា B និងអ៊ីយ៉ុង $H_3O^+$ ។

តាមសមីការលំនឹង៖ $BH^+\,(aq) + H_2O\,(l) \underset{(2)}{\overset{(1)}{\rightleftharpoons}} B\,(aq) + H_3O^+\,(aq)$

អ៊ីដ្រូលីសនៃកាចុង $BH^+$ បង្កើតបាន $H_3O^+$ ក្នុងសូលុយស្យុង ហេតុនេះហើយបានជាសូលុយស្យុងទទួលបានជាសូលុយស្យុងអាស៊ីត ។

***បាស B កាន់តែខ្សោយ អាស៊ីតឆ្លាស់ $BH^+$ កាន់តែខ្លាំង***

ឧទា. អាម៉ូញ៉ូមក្លរួ $NH_4Cl$ ជាអាស៊ីត ។

$NH_4Cl\,(s) \longrightarrow NH_4^+\,(aq) + Cl^-\,(aq)$

$Cl^-\,(aq) + H_2O \longrightarrow$ គ្មាន



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

$NH_4^+ (aq) + H_2O (l) \longrightarrow NH_3 (g) + H_3O^+ (aq)$

ដូចនេះសូលុយស្យុង $NH_4Cl$ ជាអាស៊ីត ព្រោះវាបង្កើតបាន $H_3O^+$ ក្នុងសូលុយស្យុង។

## ៤. សូលុយស្យុងតំប៉ុង

**និយមន័យ ៖** សូលុយស្យុងតំប៉ុង ជាសូលុយស្យុងដែលផ្សំដោយអាស៊ីតខ្សោយ និងបាសឆ្លាស់របស់វា ឬសូលុយស្យុងបាសខ្សោយ និងអាស៊ីតឆ្លាស់របស់វា ហើយមានកំហាប់ស្មើគ្នា ។

សូលុយស្យុងតំប៉ុង មានបម្រែបម្រួល pH តិចតួច កាលណាគេបន្ថែមអាស៊ីតខ្លាំង ឬបាសខ្លាំងបន្តិចចូល។

ឧទា. សូលុយស្យុងមាន 0,100mol នៃ $CH_3COOH$ និង 0,100mol នៃ $CH_3COONa$ ជាសូលុយស្យុងតំប៉ុង ព្រោះក្នុងសូលុយស្យុងនេះមាន $CH_3COOH$ និង $CH_3COO^-$ មានបរិមាណ 0,100 mol ដូចគ្នា។



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

# ជំពូក៥ គីមីសរីរាង្គ
## មេរៀនទី១ អេស្ទែ ខ្លាញ់ និងប្រេង

### ១. អេស្ទែ

អេស្ទែ ជាអង្គធាតុស្រឡាយនៃអាស៊ីតកាបុកស៊ីលិច( R-COOH ) ដែលបានពីការជំនួសក្រុម( -OH ) របស់អាស៊ីតដោយក្រុម( -OR′ ) របស់អាល់កុល ។

*អេស្ទែមានរូបមន្តទូទៅ ៖*



ឬ R-COOR' (R, R' អាចដូចគ្នា)

*បង្គុំនាទីអេស្ទែ៖*



ឬ -COO-C-

### ១.១ នាមវលី

ដើម្បីហៅឈ្មោះអេស្ទែ គេហៅឈ្មោះរ៉ាឌីកាល់ R′ របស់អាល់កុល រួចហៅឈ្មោះអាស៊ីតដោយប្តូរបច្ច័មបទពី " អូអ៊ិច " ទៅជា " អូអាត " ។

ឧទា. $CH_3$-COO-$C_2H_5$ អេទីល អេតាណូអាត

$C_6H_5$-COO-$C_2H_5$ អេទីល បង់សូអាត

$CH_3$-COO-$C_6H_5$ ផេនីល អេតាណូអាត

$CH_3$-CH($CH_3$)-$CH_2$-COO-$CH_2$-CH($CH_3$)-$CH_3$ 2-មេទីល ប្រូពីល 3-មេទីល ប៊ុយតាណូអាត

### ១.២ លក្ខណៈរូប

អេស្ទែភាគច្រើនដែលមានម៉ាសម៉ូលតូច រលាយក្នុងទឹក ងាយហើរ មានក្លិនគួរជាទីគាប់ចិត្ត ។ ល្បាយអេស្ទែត្រូវបានប្រើសម្រាប់ធ្វើទឹកអប់ នំ បង្អែម ភេសជ្ជ: ...។

### ១.៣ លក្ខណ:គីមី

**ក. អ៊ីដ្រូលីស៖** ជាប្រតិកម្មរវាងអេស្ទែ និងទឹក ឲ្យផលជាអាស៊ីត និងអាល់កុល ។

$$R\text{-}COO\text{-}R' + H_2O \rightleftharpoons R\text{-}COOH + R'\text{-}OH$$

$$CH_3\text{-}COO\text{-}C_2H_5 + H_2O \rightleftharpoons CH_3\text{-}COOH + C_2H_5\text{-}OH$$

**ខ. សាប៊ូកម្ម៖** អេស្ទែមានអំពើជាមួយស៊ូត ឲ្យផលជាអំបិលនៃអាស៊ីត និងអាល់កុល ។

$$R\text{-}COO\text{-}R' + NaOH \longrightarrow R\text{-}COONa + R'\text{-}OH$$

$$CH_3\text{-}COO\text{-}C_2H_5 + NaOH \longrightarrow CH_3\text{-}COONa + C_2H_5\text{-}OH$$

**គ. ប្រតិកម្មជាមួយអាម៉ូញាក់៖** អាម៉ូញាក់មានអំពើជាមួយអេស្ទែ ឲ្យជាអាមីតនិងអាល់កុល ។

$$R\text{-}COO\text{-}R' + NH_3 \longrightarrow R\text{-}CO\text{-}NH_2 + R'\text{-}OH$$

$$CH_3\text{-}COO\text{-}C_2H_5 + NH_3 \longrightarrow CH_3\text{-}CO\text{-}NH_2 + C_2H_5\text{-}OH$$

**ឃ. ប្រតិកម្មរេដុកម្មអេស្ទែ៖** អេស្ទែរងរេដុកម្មជាអាល់កុលដោយអ៊ីដ្រូសែននៅចំពោះមុខកាតាលីករ ដូចជាល្បាយនៃ CuO,$CuCr_2O_4$ ឬ $LiAlH_4$ នៅសីតុណ្ហភាព និងសម្ពាធខ្ពស់។



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

$R\text{-}COO\text{-}R' + 2H_2 \longrightarrow R\text{-}CH_2\text{-}OH + R'\text{-}OH$

$CH_3\text{-}COO\text{-}C_3H_7 + 2H_2 \longrightarrow CH_3\text{-}CH_2\text{-}OH + C_3H_7\text{-}OH$

## ១.៤ ទង្វើអេស្ទែ

*អេស្ទែអាចធ្វើឡើងតាមពីររបៀប៖*

**ក. អេស្ទែកម្ម៖** ជាប្រតិកម្មរវាងអាស៊ីត និងអាល់កុល ឲ្យជាអេស្ទែនិងទឹក ។

$R\text{-}COOH + R'\text{-}OH \rightleftharpoons R\text{-}COO\text{-}R' + H_2O$

$CH_3\text{-}COOH + C_2H_5\text{-}OH \rightleftharpoons CH_3\text{-}COO\text{-}C_2H_5 + H_2O$

**ខ. ប្រតិកម្មរវាងអានីទ្រីតអាស៊ីតឬអាស៊ីលក្លរួនិងអាល់កុល**

-អានីទ្រីតអាស៊ីតមានអំពើជាមួយអាល់កុល ឲ្យជាអេស្ទែនិងអាស៊ីត។

$R\text{-}CO\text{-}O\text{-}CO\text{-}R + R'\text{-}OH \longrightarrow R\text{-}COO\text{-}R' + R\text{-}COOH$

$CH_3\text{-}CO\text{-}O\text{-}CO\text{-}CH_3 + C_2H_5\text{-}OH \longrightarrow CH_3\text{-}COO\text{-}C_2H_5 + CH_3\text{-}COOH$

-អាស៊ីលក្លរួមានអំពើជាមួយអាល់កុល ឲ្យជាអេស្ទែនិងអាស៊ីតក្លរីឌ្រិច។

$R\text{-}CO\text{-}Cl + R'\text{-}OH \longrightarrow R\text{-}COO\text{-}R' + HCl$

$CH_3\text{-}CO\text{-}Cl + C_2H_5\text{-}OH \longrightarrow CH_3\text{-}COO\text{-}C_2H_5 + HCl$

## ១.៥-អេស្ទែសំខាន់ៗ



មេទីលបង់សូអាត



អាស៊ីតសាលីស៊ីលិច



មេទីលសាលីស៊ីឡាត



អាស៊ីតអាសេទីលសាលីស៊ីលិច(អាស្ពីរីន)

**ទង្វើអាស្ពីរីន**



អាស៊ីតសាលីស៊ីលិច អានីឌ្រីតអាសេទិច អាស្ពីរីន អាស៊ីតអាសេទិច

## ២. ខ្លាញ់ និងប្រេង

ខ្លាញ់ និងប្រេងមានច្រើននៅក្នុងធម្មជាតិ វាបង្កសំខាន់នៅក្នុងកោសិកាសត្វនិងរុក្ខជាតិ ។ ខ្លាញ់បានពីសត្វ ហើយប្រេងបានពីរុក្ខជាតិ។

## ២.១ សមាសភាព

ខ្លាញ់ និងប្រេងមានទម្រង់ដូចគ្នា គឺជាទ្រីអេស្ទែដែលកើតពីគ្លីសេរ៉ុល ឬ ប្រូប៉ាន -1,2,3-ទ្រីអុល ( $CH_2OH\text{-}CHOH\text{-}CH_2OH$) និងអាស៊ីតខ្លាញ់ ។

$$\begin{array}{l} CH_2\text{–}OH \\ CH\text{–}OH \\ CH_2\text{–}OH \end{array} + 3R\text{-}COOH \longrightarrow \begin{array}{l} CH_2\text{–}OCO\text{–}R \\ CH\text{–}OCO\text{–}R \\ CH_2\text{–}OCO\text{–}R \end{array} + 3H_2O$$

គ្លីសេរ៉ុល អាស៊ីតកាបុកស៊ីលិច ខ្លាញ់ ឬ ប្រេង ទឹក

**អាស៊ីតខ្លាញ់ឆ្អែត**

-អាស៊ីតប៉ាល់មីទិច $CH_3\text{-}(CH_2)_{14}\text{-}COOH$

-អាស៊ីតស្តេអារិច $CH_3\text{-}(CH_2)_{16}\text{-}COOH$

-អាស៊ីតអារ៉ាស៊ីឌិច $CH_3\text{-}(CH_2)_{18}\text{-}COOH$



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

### អាស៊ីតខ្លាញ់មិនឆ្អែត

-អាស៊ីតអូលេអ៊ិច $CH_3-(CH_2)_7-CH=CH-(CH_2)_7-COOH$

-អាស៊ីតលីណូលេអ៊ិច $CH_3-(CH_2)_4-CH=CH-CH_2-CH=CH-(CH_2)_7-COOH$

-អាស៊ីតលីណូលេនិច

$CH_3-CH_2-CH=CH-CH_2-CH=CH-CH_2-CH=CH-(CH_2)_7-COOH$

-អាស៊ីតអារ៉ាស៊ីដូនិច

$CH_3-(CH_2)_3-CH=CH-CH_2-CH=CH-CH_2-CH=CH-CH_2-CH=CH-(CH_2)_4-COOH$

### ឧទាហរណ៍



គ្លីសេរ៉ុល អាស៊ីតប៉ាល់មីទិច គ្លីសេរីលទ្រីប៉ាល់មីតាត ទឹក

## ២.២ លក្ខណៈខ្លាញ់ ឬប្រេង

ខ្លាញ់ និងប្រេងស្រាលជាងទឹក មិនរលាយក្នុងទឹក តែរលាយក្នុងឌីក្លរ៉ូអេតាន អេទែបង់សែន ប្រេងសាំង កាបូនតេត្រាក្លរួ ឌីក្លរ៉ូអេទីឡែន ។

### ក-អ៊ីដ្រូសែនកម្ម

ប្រេងរុក្ខជាតិរាវជាសមាសធាតុមិនឆ្អែតវាអាចរងអ៊ីដ្រូសែនកម្មទៅជាខ្លាញ់រឹង ។

$$\begin{matrix} CH_2–OCO–(CH_2)_7–CH=CH–(CH_2)_7–CH_3 \\ CH–OCO–(CH_2)_7–CH=CH–(CH_2)_7–CH_3 \\ CH_2–OCO–(CH_2)_7–CH=CH–(CH_2)_7–CH_3 \end{matrix} + 3H_2 \xrightarrow[t]{Ni} \begin{matrix} CH_2–OCO–(CH_2)_{16}–CH_3 \\ CH–OCO–(CH_2)_{16}–CH_3 \\ CH_2–OCO–(CH_2)_{16}–CH_3 \end{matrix}$$

គ្លីសេរីលទ្រីអូលេអាត(ប្រេងរាវ) គ្លីសេរីលទ្រីស្តេអារ៉ាត(ខ្លាញ់រឹង)

### ខ-អ៊ីដ្រូលីសខ្លាញ់ ឬប្រេង

នៅពេលគេដុតកម្តៅទ្រីគ្លីសេរីតជាមួយបាស គេបានគ្លីសេរុលនិងអំបិលនៃអាស៊ីតខ្លាញ់។

$$\begin{matrix} CH_2–OCO–(CH_2)_{14}–CH_3 \\ CH–OCO–(CH_2)_{14}–CH_3 \\ CH_2–OCO–(CH_2)_{14}–CH_3 \end{matrix} + 3NaOH \longrightarrow \begin{matrix} CH_2–OH \\ CH–OH \\ CH_2–OH \end{matrix} + 3CH_3–(CH_2)_{14}–COONa$$

សូដ្យូមប៉ាល់មីតាត(សាប៊ូ)

ទ្រីប៉ាល់មីទីន ឬ គ្លីសេរីលទ្រីប៉ាល់មីតាត គ្លីសេរ៉ុល

*ប្រតិកម្មនេះហៅថាប្រតិកម្មសាប៊ូកម្ម។*

## ២.៣ បំលែងខ្លាញ់ក្នុងសារពាង្គកាយ

ខ្លាញ់ និងប្រេងជាអាហារផ្តល់ថាមពលកម្តៅច្រើនជាងប្រូតេអ៊ីននិងកាបូនអ៊ីដ្រាត ។ ក្រោមអំពើរបស់សេលំពែង និងពោះវៀន ខ្លាញ់ និងប្រេងរងអ៊ីដ្រូលីសក្លាយជាគ្លីសេរ៉ុលនិងអាស៊ីតខ្លាញ់ដែលអាចស្រូបដោយស្រទាប់ពោះវៀន បន្ទាប់មកសំយោគទៅជាទ្រីគ្លីសេរីតជាថ្មីស្តុកទុកក្នុងកោសិកាខ្លាញ់ ហើយបញ្ជូនទៅឲ្យសរីរាង្គផ្សេងៗដែលវាត្រូវរងអ៊ីដ្រូលីស និងអុកស៊ីតកម្ម



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

ទៅជា$CO_2$ និង$H_2O$ ។ ប្រតិកម្មនេះបញ្ចេញកម្តៅឲ្យសារពាង្គកាយសម្រាប់ទ្រទ្រង់សកម្មភាពជីវិត ។

## ២.៤ សាប៊ូ

សាប៊ូ ជាល្បាយអំបិលសូដ្យូម ឬប៉ូតាស្យូមនៃអាស៊ីតកាបុកស៊ីលិចដែលមានខ្សែកាបូនយ៉ាងវែង(មានកាបូនពី១២ទៅ១៨) គ្មានខ្នែង ។ អំបិលប៉ូតាស្យូមបង្កើតបានសាប៊ូទន់ ជាងអំបិលសូដ្យូម។




ទម្រង់ម៉ូលេគុលសាប៊ូ



កន្ទុយ(អ៊ីដ្រូផូប) ក្បាល(អ៊ីដ្រូភីល)

***អ៊ីដ្រូភីល ឬលីប៉ូផូប*** គឺជាផ្នែកក្បាលរបស់សាប៊ូ ($–COO^-$) មានលក្ខណៈចំណូលទឹក មិនចំណូលខ្លាញ់ និងប្រេងទេ។

***អ៊ីដ្រូផូប ឬលីប៉ូភីល*** គឺជាខ្សែកាបូន ផ្នែកកន្ទុយរបស់សាប៊ូ មានទំនោរចូលចិត្តខ្លាញ់ និងប្រេង មិនចំណូលទឹកទេ។

**-អំពើរបស់សាប៊ូទៅលើស្នាមប្រឡាក់៖** ស្នាមប្រឡាក់លើសម្លៀកបំពាក់ ឬស្បែកគឺជាប្រេង ឬខ្លាញ់ និងធូលីផ្សេងៗ ។ ប្រេង ឬខ្លាញ់វាត្រូវបានដកចេញពីស្នាមប្រឡាក់ដោយការលាងជម្រះ ។ មុខងារសម្អាតរបស់សាប៊ូទាក់ទងទៅនឹងទម្រង់គីមីរបស់វា ។ ពេលសាប៊ូរលាយក្នុងទឹក ម៉ូលេគុលរបស់វាបង្កើតជាមីសែល។ ផ្នែកអ៊ីដ្រូផូបរុំព័ទ្ធខ្លាញ់(ក្អែល) ចំណែកផ្នែកអ៊ីដ្រូភីលបែរចេញក្រៅ ។




ម៉ូលេគុលសាប៊ូលើផ្ទៃទឹក




ពពុះសាប៊ូ




កំណាមីសែលក្នុងទឹក



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

**ចំណាំ ៖** គេមិនអាចប្រើសាប៊ូជាមួយទឹករឹងទេ ព្រោះវាបង្កឲ្យមានកករជាមួយអ៊ីយ៉ុង $Ca^{2+}$ និង $Mg^{2+}$ មិនបានទៅជម្រះក្អែល ឬខ្លាញ់ និងប្រេងទេ។ ទឹករឹង គឺជាទឹកមានបរិមាណអ៊ីយ៉ុង $Ca^{2+}$និង $Mg^{2+}$ ច្រើន។

សមីការ ៖ $2\,R{-}COO^{-} + Ca^{2+} \rightarrow (R{-}COO)_2Ca_{(s)}$

$2\,R{-}COO^{-} + Mg^{2+} \rightarrow (R{-}COO)_2Mg_{(s)}$

**ឧទាហរណ៍**

$2CH_3\text{-}(CH_2)_8\text{-}COO^- + Ca^{2+} \rightarrow [CH_3\text{-}(CH_2)_8\text{-}COO]_2Ca$

$2CH_3\text{-}(CH_2)_8\text{-}COO^- + Mg^{2+} \rightarrow [CH_3\text{-}(CH_2)_8\text{-}COO]_2Mg$

**ដូចនេះ** ដើម្បីបោកគក់ជម្រះស្នាមប្រលាក់នៅក្នុងទឹករឹង គេប្រើសារធាតុជម្រះក្អែលដែលមានលក្ខណៈប្រសើរជាងសាប៊ូ ព្រោះសារធាតុជម្រះក្អែលមិនបង្កើតកករជាមួយអ៊ីយ៉ុង $Ca^{2+}$និង $Mg^{2+}$នៅក្នុងទឹករឹងទេ ។

## ២.៥-សារធាតុជម្រះក្អែល

មានលក្ខណៈដូចសាប៊ូដែរ ប៉ុន្តែវាមានក្បាលជា $-SO_3^-$ ឬ $-0SO_3^-$។ សារធាតុជម្រះអាចប្រើក្នុងទឹករឹង ដោយវាមិនបង្កើតកករជាមួយនឹងអ៊ីយ៉ុងកាល់ស្យូម ឬម៉ាញេស្យូម ឬ សង្ក័សីទេ។

**ទូទៅ**

- **សូដ្យូមអាល់គីលបង់សែនស៊ុលផូណាត**




(R អាចមានអាតូមកាបូនពី12 ទៅ18)

- **សូដ្យូមអាល់គីលស៊ុលផាត**

$R\text{-}OSO_3Na$

**ឧទាហរណ៍**




សូដ្យូមប៉ង់ដេគីលបង់សែនស៊ុលផូណាត

$CH_3 – (CH_2)_{10} – CH_2 – OSO_3Na$

សូដ្យូមឡូរីស៊ុលផាត

## ២.៦ ថ្នាំលាប

ថ្នាំលាបផ្សំដោយសារធាតុសំខាន់បីយ៉ាងគឺ ៖ សារធាតុភ្ជាប់ ជាតិពណ៌ និងធាតុរំលាយ ។



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

- ***សារធាតុភ្ជាប់*** ដែលអាចស្អិតភ្ជាប់ទៅនឹងផ្ទៃដែលត្រូវលាប បង្ខាំងជាតិពណ៌ឲ្យនៅក្នុងកន្លែងរបស់វា និងជារនាំងការពារសំណើម។
- ***ជាតិពណ៌*** ដែលផ្តល់ពណ៌ឲ្យទៅថ្នាំលាប ជាអ្នកស្រោប និងការពារអនុភាពរបស់ថ្នាំ។
- ***ធាតុរំលាយ*** សម្រាប់ជួយសម្រួលនៅពេលលាបថ្នាំ និងបន្ទាប់មកត្រូវហួតអស់។

---



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

# មេរៀនទី២ ស្រលាយអាលីផា និងអាសូត

## ១. អាមីន

### ១.១ រូបមន្ត និងនាមវលី

**ក-រូបមន្ត**

អាមីន ជាសមាសធាតុសរីរាង្គ ដែលបានពីការជំនួសអាតូមអ៊ីដ្រូសែនរបស់ម៉ូលេគុល $NH_3$ ដោយរ៉ាឌីកាល់អ៊ីដ្រូកាបួ (R)។

H - N - H   ឬ $NH_3$ ⇨ R - N - H   ឬ   R-$NH_2$
      |                      |
      H                      H

អាម៉ូញ៉ាក       អាមីន

R ជារ៉ាឌីកាល់អ៊ីដ្រូកាបួខ្សែបើក ។ បើ R ជារ៉ាឌីកាល់អ៊ីដ្រូកាបួឆ្អែតគេបានរូបមន្តទូទៅ $C_nH_{2n+1}$-$NH_2$ ឬ $C_nH_{2n+3}N$ ។

**ខ-ចំណាត់ថ្នាក់អាមីន**

គេចែកអាមីនជាបីថ្នាក់ទៅតាមចំនួនអាតូមអ៊ីដ្រូសែនរបស់អាម៉ូញាក់ដែលត្រូវជំនួសដោយរ៉ាឌីកាល់ R ។

$R_1$ – N – H  អាមីនថ្នាក់ទីI,   $R_1$ – N – $R_2$  អាមីនថ្នាក់ទីII,   $R_1$ – N – $R_2$  អាមីនថ្នាក់ទីIII
      |                    |                    |
      H                    H                    $R_3$

**គ-នាមវលី**

-អាមីនថ្នាក់ទីI ហៅឈ្មោះរ៉ាឌីកាល់ (R) រួចបន្ថែមបច្ច័មបទ **អាមីន** ។

ឧទា. ក. $CH_3$-$NH_2$  មេទីលឡាមីន    ខ. $CH_3$-$CH_2$-$NH_2$  អេទីលឡាមីន

គ. $CH_3$-$CH_2$-CH-$CH_2$-$NH_2$ (CH ភ្ជាប់ $CH_3$)  2-មេទីល ប៊ុយទីលឡាមីន

ឃ. $CH_3$-$CH_2$-CH-$CH_2$-$CH_2$ (CH ភ្ជាប់ $NH_2$)  1-អេទីល ប្រូពីលឡាមីន

-អាមីនថ្នាក់ទីII ឬ ថ្នាក់ទី III

ទី១ ហៅឈ្មោះរ៉ាឌីកាល់(R) ដែលដែលមានខ្សែកាបូនខ្លីដោយបញ្ជាក់ទីតាំង N- ( ឬ N,N- ក្នុងករណីមានរ៉ាឌីកាល់ពីរ ) ។

ទី២ ហៅឈ្មោះដូចអាមីនថ្នាក់ទីI ចំពោះរ៉ាឌីកាល់ដែលមានខ្សែកាបូនវែង ឬសាំញ៉ាំ។

**ឧទាហរណ៍**

ក. $C_2H_5$-NH-$CH_3$   N-មេទីល អេទីលឡាមីន

ខ. $CH_3$-NH-$CH_3$   N-មេទីល មេទីលឡាមីន

គ. $C_2H_5$-N-$CH_3$ (N ភ្ជាប់ $CH_3$)   N,N-ឌីមេទីល អេទីលឡាមីន

ឃ. $C_6H_5$-N-$C_2H_5$ (N ភ្ជាប់ $CH_3$)   N-អេទីល N-មេទីល ផេនីលឡាមីន



facebook.com/moeys.gov.kh   www.moeys.gov.kh   google.com/+moeys

## ១.២ លក្ខណៈរូប

អាមីនដែលមានភាពរូបជាឧស្ម័នមានក្លិនពុំសូវល្អ ព្រោះមានលាយអាម៉ូញាក់ ។ អាមីនដែលមានម៉ាសម៉ូលធំមាន កាបូនពី 6 ឡើងទៅ មិនរលាយក្នុងទឹកទេ ប៉ុន្តែរលាយក្នុងអង្គធាតុរំលាយសរីរាង្គ ។ អាមីនមានចំណុចរំពុះខ្ពស់ជាងអាល់កាន តែទាបជាងអាល់កុលដែលមានម៉ាសម៉ូលប្រហែលគ្នា ។ ក្នុងចំណោមអ៊ីសូមែរបស់វា អាមីនថ្នាក់ទី I មានចំណុចរំពុះខ្ពស់ជាងគេ ហើយអាមីនថ្នាក់ III ទាបជាងគេ ។

## ១.៣ លក្ខណៈគីមី

- **លក្ខណៈជាបាសនៃអាម៉ូញាក់**

  $NH_3$ មានលក្ខណៈជាបាស ហើយអាស៊ីតឆ្លាស់របស់វាគឺ $NH_4^+$។ វាបង្កើតបានជាគូអាស៊ីត-បាស $NH_4^+/NH_3$ ។

  $NH_3 + H_2O \rightleftharpoons NH_4^+ + OH^-$

- **លក្ខណៈជាបាសនៃអាមីន**

អេទីលឡាមីន $C_2H_5\text{-}NH_2$ រលាយក្នុងទឹក បង្កើតជាសូលុយស្យុងបាស ។ កំហាប់ 0,1M មាន pH= 11,9 នៅ 25ºC ។ ដូចនេះ អេទីលឡាមីន ជាបាសខ្សោយ ។

$C_2H_5\text{-}NH_2 + H^+ \rightleftharpoons C_2H_5\text{-}NH_3^+$

$C_2H_5\text{-}NH_2 + H_2O \rightleftharpoons C_2H_5\text{-}NH_3^+ + OH^-$

ជាទូទៅ អាមីនទាំងអស់ជាបាសខ្សោយ ប៉ុន្តែខ្លាំងជាងអាម៉ូញាក់ ។

$R\text{-}NH_2 \rangle NH_3 \rangle C_6H_5\text{-}NH_2$

- **ប្រតិកម្មរវាងអាមីន និងអង្គធាតុស្រលាយអាឡូសែន (R-X)**

$R_1-N(R_3)-R_2 + C_2H_5-I \rightarrow R_1-N^+(C_2H_5)(R_3)-R_2 + I^-$

(អេទីលអ៊ីយ៉ូដួ)

Ex.

$CH_3-N(CH_3)-CH_3 + CH_3-I \rightarrow CH_3-N^+(CH_3)(CH_3)-CH_3 + I^-$

(មេទីលអ៊ីយ៉ូដួ)

- **ប្រតិកម្មអាមីនថ្នាក់ I ជាមួយអាស៊ីលក្លរួ (R-CO-Cl)**

$R-CO-Cl + R_1-NH_2 \rightarrow R-CO-NH-R_1 + HCl$

Ex. $CH_3-CO-Cl + CH_3-NH_2 \rightarrow CH_3-CO-NH-CH_3 + HCl$

- **ប្រតិកម្មបង្កើតអំបិល**

$R-NH_2 + HCl \rightarrow R-NH_3^+ + Cl^-$

## ១.៤ ទង្វើអាមីន

- *អាម៉ូញាក់មានអំពើជាមួយអាល់គីលអាឡូសែន ឲ្យជាអាមីនថ្នាក់ ទី I*

$R-X + NH_3 \rightarrow R-NH_2 + HX$

$C_2H_5-Cl + NH_3 \rightarrow C_2H_5-NH_2 + HCl$



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

អាមីនថ្នាក់ទី I កកើតធ្វើប្រតិកម្មជាមួយ R-X បង្កើតអាមីនថ្នាក់ទី II , អាមីនថ្នាក់ទី II ក៏ធ្វើប្រតិកម្មបន្តជាមួយ R-X បង្កើត អាមីនថ្នាក់ទី III។ អាមីនថ្នាក់ទី III ក៏ធ្វើប្រតិកម្មបន្តបង្កើតជាអំបិលអាម៉ូញ៉ូម។

$$R-X \xrightarrow{NH_3} R-NH_2 \xrightarrow{R-X} R-NH-R \xrightarrow{R-X} R_3N$$

- $R\text{-}X + NH_3 \rightarrow R\text{-}NH_2 + HX$ (អាមីនថ្នាក់ទី I )
- $R\text{-}NH_2 + R\text{-}X \rightarrow R\text{-}NH\text{-}R + HX$ (អាមីនថ្នាក់ទី II )
- $R\text{-}NH\text{-}R + R\text{-}X \rightarrow R_3N + HX$ (អាមីនថ្នាក់ទី III )
- $R_3N + R\text{-}X \rightarrow R_4NX$ (អំបិលអាម៉ូញ៉ូម)

## ឧទាហរណ៍

- $CH_3\text{-}Cl + NH_3 \rightarrow CH_3\text{-}NH_2 + HCl$
- $CH_3\text{-}NH_2 + CH_3\text{-}Cl \rightarrow CH_3\text{-}NH\text{-}CH_3 + HCl$
- $CH_3\text{-}NH\text{-}CH_3 + CH_3\text{-}Cl \rightarrow (CH_3)_3N + HCl$
- $(CH_3)_3N + CH_3\text{-}Cl \rightarrow (CH_3)_4NCl$

- ***ប្រតិកម្មរេដុកម្មនៃក្រុមនីទ្រីល ផ្តល់បានអាមីនថ្នាក់ទី I***

$$R-C\equiv N + 4(H) \xrightarrow{Ni\ \ 200atm} R-CH_2-NH_2$$

$$CH_3-CH_2-CH_2-CH_2-C\equiv N + 4(H) \xrightarrow{Ni,t,p} CH_3-CH_2-CH_2-CH_2-CH_2-NH_2$$

ប៉ង់តាននីទ្រីល ប៉ង់ទីលឡាមីន

# ២. អាមីត

## ២.១ រូបមន្ត និងនាមវលី

### ក-រូបមន្ត

**អាមីត** គឺជាស្រលាយនៃអាស៊ីតកាបុកស៊ីលិច(R-COOH)ដែលក្នុងនោះបង្គុំ(-OH) របស់អាស៊ីតត្រូវបានជំនួសដោយបង្គុំអាមីន($-NH_2$)។

*រូបមន្តទូទៅនៃអាមីត* ៖ $R\text{-}CO\text{-}NH_2$

អាតូមអ៊ីដ្រូសែនរបស់បង្គុំ ($-NH_2$)ជំនួសដោយរ៉ាឌីកាល់អ៊ីដ្រូកាបួ បង្កើតជាថ្នាក់អាមីត ។

| $R-CO-NH_2$ | $R-CO-NH-R_1$ | $R-CO-N(R_2)-R_1$ |
|---|---|---|
| អាមីតថ្នាក់ទី I | អាមីតថ្នាក់ទី II | អាមីតថ្នាក់ទី III |

### ខ-នាមវលី (IUPAC)

ឈ្មោះរបស់អាមីតបានមកពីឈ្មោះអាស៊ីតដោយប្តូរបច្ច័មបទ**អូអ៊ិច**របស់អាស៊ីតទៅជា**អាមីត**។

| ឧទា. | $H\text{-}CO\text{-}NH_2$ | $CH_3\text{-}CO\text{-}NH_2$ | $CH_3\text{-}CH_2\text{-}CO\text{-}NH_2$ |
|---|---|---|---|
| **(IUPAC) ៖** | មេតាណាមីត | អេតាណាមីត | ប្រូប៉ាណាមីត |
| **(ឈ្មោះធ្លាប់ប្រើ)៖** | ផរម៉ាមីត | អាសេតាមីត | ប្រូប្យ៉ូណាមីត |



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

-ដើម្បីហៅឈ្មោះអាមីតថ្នាក់ទី II និងថ្នាក់ទី III គេត្រូវហៅរ៉ាឌីកាល់អ៊ីដ្រូកាបួដោយបញ្ជាក់ទីតាំង N- ឬ N,N- ។

**ឧទាហរណ៍៖** $CH_3-CO-NH-CH_3$ N-មេទីល អេតាណាមីត

$CH_3-CO-N(CH_3)-CH_3$ N,N-ឌីមេទីល អេតាណាមីត

## ២.២ លក្ខណៈរូប និងគីមី

អាមីតមានចំណុចរំពុះខ្ពស់ ។ អាមីតភាគច្រើនមានទម្រង់ជាក្រាមរឹង។ អាមីតរលាយក្នុងទឹកបានច្រើនជាងអាល់កុលបន្តិច កាលណាម៉ូលេគុលទាំងពីរមានចំនួនអាតូមកាបូនស្មើគ្នា។

ដោយដុតកម្ដៅជាមួយទឹក អាមីតរងអ៊ីដ្រូលីសយឺតៗបង្កើតបានជាអាស៊ីតកាបុកស៊ីលិច និងអាម៉ូញាក់។

$$CH_3-CO-NH_2 + H-OH \xrightarrow{t} CH_3-COOH + NH_3$$

អេតាណាមីត អាស៊ីតអាសេទិច

## ២.៣ ទង្វើអាមីត

-ប្រតិកម្មរវាងអេស្ទែ និងអាម៉ូញាក់

$$CH_3-COO-C_2H_5 + NH_3 \longrightarrow CH_3-CO-NH_2 + C_2H_5-OH$$

-ប្រតិកមម្មរវាងអាស៊ីលក្លរួ និងអាម៉ូញាក់

$$CH_3-CO-Cl + 2NH_3 \longrightarrow CH_3-CO-NH_2 + NH_4Cl$$

-ប្រតិកម្មរវាងអានីឌ្រីតអាស៊ីត និងអាម៉ូញាក់

$$CH_3-CO-O-CO-CH_3 + NH_3 \longrightarrow CH_3-CO-NH_2 + CH_3-COOH$$

-ប្រតិកម្មរវាងអាស៊ីតកាបុកស៊ីលិច និងអាម៉ូញាក់:

$$CH_3-COOH + NH_3 \longrightarrow CH_3-CO-NH_2 + H_2O$$

## ២.៤ អាមីតពិសេស(អ៊ុយរ៉េ)

អ៊ុយរ៉េ ឬ កាបាមីត(carbamide) គឺជាឌីអាមីននៃក្រុមកាបូនីល ។

$H_2CO_3$ អាស៊ីតកាបូនិច $H_2N-CO-NH_2$ អ៊ុយរ៉េ

***ទង្វើ៖*** $CO_2 + 2NH_3 \longrightarrow H_2N-CO-NH_2 + H_2O$

# ៣. អាស៊ីតអាមីណេ

## ៣.១ ទម្រង់ម៉ូលេគុល និងនាមវលី

### ក-ទម្រង់ម៉ូលេគុល

អាស៊ីតអាមីណេ គឺជាសមាសធាតុសរីរាង្គដែលមានបង្គុំកាបុកស៊ីល (-COOH ) មួយ



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

និងបង្គុំអាមីន( $-NH_2$ ) មួយ ។ កាលណាបង្គុំទាំងពីរភ្ជាប់នឹងអាតូមកាបូនតែមួយ គេបាន អាស៊ីត α-អាមីណេ ។

រូបមន្តទូទៅនៃអាស៊ីត α-អាមីណេ ៖ $R-\overset{\alpha}{C}H(NH_2)-COOH$

### ខ-នាមវលី

គេហៅអាស៊ីតអាមីណេតាមឈ្មោះធ្លាប់ប្រើ ។ កាលណាបង្គុំអាមីនជាប់នឹងអាតូមកាបូនក្នុងទីតាំង β ឬ γ ឈ្មោះអាស៊ីតអាមីណេត្រូវបន្ថែមបុព្វបទ β-អាមីណូ ឬ γ-អាមីណូទៅលើឈ្មោះអាស៊ីតកាបុកស៊ីលិច ។

ឧទា. $H-\overset{\alpha}{C}H(NH_2)-COOH$ អាស៊ីត α-អាមីណូអាសេទិច (គ្លីស៊ីន Glycine)

$CH_3-\overset{\alpha}{C}H(NH_2)-COOH$ អាស៊ីត α-អាមីណូប្រូប៉្យូនិច (អាឡាលីន Alanine)

$H_2N-\overset{\beta}{C}H_2-\overset{\alpha}{C}H_2-COOH$ អាស៊ីត β-អាមីណូប្រូប៉្យូនិច

$H_2N-\overset{\gamma}{C}H_2-\overset{\beta}{C}H_2-\overset{\alpha}{C}H_2-COOH$ អាស៊ីត γ-អាមីណូប៊ុយទីរិច

### ៣.២ លក្ខណៈ

- អាស៊ីតអាមីណេ គឺជាអង្គធាតុក្រាមដែលរលាយ ឬបំបែកនៅសីតុណ្ហភាពខ្ពស់ ។ វាងាយរលាយក្នុងទឹក ប៉ុន្តែមិនរលាយក្នុងអង្គធាតុរំលាយសរីរាង្គ ដូចជា បង់សែន អាល់កុល អេទែ... ទេ។
- ក្នុងម៉ូលេគុលអាស៊ីតអាមីណេ បង្គុំកាបុកស៊ីលមានលក្ខណៈជាអាស៊ីត ឯបង្គុំអាមីនមានលក្ខណៈជាបាស ។

នៅក្នុងភាពជាសូលុយស្យុងទឹក អាស៊ីតអាមីណេមានទម្រង់បីបែប ៖

$R-CH(NH_3^+)-COO^-$ ក្នុងសូលុយស្យុងណឺត

$R-CH(NH_3^+)-COOH$ ក្នុងសូលុយស្យុងអាស៊ីត

$R-CH(NH_2)-COO^-$ ក្នុងសូលុយស្យុងបាស

ប្រភេទទាំងបីស្ថិតនៅក្នុងគូអាស៊ីត/បាសពីរ ៖

$$R-CH(NH_3^+)-COOH \rightleftharpoons R-CH(NH_3^+)-COO^- + H^+$$

$$R-CH(NH_3^+)-COO^- \rightleftharpoons R-CH(NH_2)-COO^- + H^+$$

អាស៊ីតអាមីណេ មានលក្ខណៈអំផូទែ គឺវាអាចចាប់យកប្រូតុងពីអាស៊ីតខ្លាំង ឬផ្តល់ប្រូតុងទៅបាសខ្លាំង ។



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

### ៣.៣ ទង្វើ

មានវិធីជាច្រើនដើម្បីបង្កើតអាស៊ីតអាមីណេ។

**ក-វិធីទី១**

គេឲ្យអាស៊ីត α-អាឡូសែណូកាបុកស៊ីលិច មានប្រតិកម្មជាមួយអាម៉ូញាក់ គេទទួលបាន អាស៊ីត α-អាមីណូកាបុកស៊ីលិច ។

$$\underset{|\atop Cl}{CH_2}-COOH + 2NH_3 \longrightarrow \underset{|\atop NH_2}{CH_2}-COOH + NH_4Cl$$

អាស៊ីតក្លរ៉ូអាសេទិច ក្លីស៊ីន

**ខ-វិធីទី២**

គេឲ្យអាល់ដេអ៊ីតមានអំពើជាមួយអ៊ីដ្រូសែនស្យានួ ចំពោះវត្តមានអាម៉ូញាក់ បង្កើតបានជា អាមីណូនីទ្រីល ។ អ៊ីដ្រូលីសអាមីណូនីទ្រីលផ្តល់អាស៊ីតអាមីណេ ។

$$CH_3-CHO \xrightarrow[NH_3]{HCN} CH_3-\underset{|\atop NH_2}{CH}-C\equiv N \xrightarrow[H^+]{H_2O} CH_3-\underset{|\atop NH_2}{CH}-COOH$$

អាសេតាល់ដេអ៊ីត អាមីណូនីទ្រីល អាឡានីន

### ៣.៤ ប៉ិបទីត និងប្រូតេអ៊ីន

**ក-សម្ព័ន្ធប៉ិបទីត**

សម្ព័ន្ធប៉ិបទីត (-CO-NH- ) កើតឡើងដោយម៉ូលេគុលអាស៊ីតអាមីណេចំនួនពីរភ្ជាប់គ្នា ដោយការដកទឹកចេញចំនួន ១ ម៉ូលេគុល។




ក្លីស៊ីន (Gly) អាឡានីន (Ala) ក្លីស៊ីលអាឡានីន (Gly-Ala)

- ប៉ិបទីតដែលបង្កដោយអាស៊ីតអាមីណេចំនួន ៣ , ៤ ឬ ៥ មានឈ្មោះថា ទ្រីប៉ិបទីត តេត្រាប៉ិបទីត ប៉ង់តាប៉ិបទីត។
- ប៉ិបទីតដែលបង្កដោយអាស៊ីតអាមីណេតិចជាង 60 ហៅថា ប៉ូលីប៉ិបទីត ។
- ប៉ិបទីតដែលបង្កដោយអាស៊ីតអាមីណេច្រើនជាង 60 ហៅថា **ប្រូតេអ៊ីន** ។
- ប្រូតេអ៊ីនធម្មជាតិផ្តល់អាស៊ីតអាមីណេចំនួន 20 ប្រភេទដែលក្នុងនោះមាន អាស៊ីតអាមីណេចំនួន ៨ ដែលមនុស្សត្រូវផ្តល់ឲ្យសារពាង្គកាយមិនអាចខ្វះបានតាមរយៈ អាហារព្រោះសរីរាង្គមនុស្សមិនអាចសំយោគវាបាន។
- អាស៊ីតអាមីណេចំនួន៨ដែលសំខាន់សម្រាប់សារពាង្គកាយរួមមាន៖ វ៉ាលីន ឡឺស៊ីន អ៊ីសូឡឺស៊ីន ត្រេអូនីន មេត្យូនីន លីស៊ីន ផេនីឡាមីន និង ទ្រីបតូផាន។



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

# មេរៀនទី៣ សមាសធាតុប្រហើរ

សមាសធាតុប្រហើរ ជាសមាសធាតុសរីរាង្គដែលមានវង់បង់សែន($C_6H_6$) ឬ  ក្នុងសមាសធាតុរបស់វា។

**ប្រតិកម្មជំនួសសំខាន់ៗដែលកើតមានលើបង់សែនរួមមាន៖**

-ប្រតិកម្មក្លរកម្ម(បូកក្លរ $Cl_2$ ):




-ប្រតិកម្មប្រូមកម្ម(បូកប្រូម $Br_2$ ):




-ប្រតិកម្មនីទ្រកម្ម(បូក $HNO_3$ ):




-ប្រតិកម្មស៊ុលផូកម្ម(បូក $H_2SO_4$ ):




-ប្រតិកម្មអាល់គីលកម្ម(បូក R-X):




**ចំណាំ**




ទីតាំងអរតូ(0) ទីតាំងមេតា(m) ទីតាំងប៉ារ៉ា(p)

## ១. ស្រឡាយបង់សែន

**- នីត្រូបង់សែន** កើតពីប្រតិកម្មរវាងបង់សែន ជាមួយអាស៊ីតនីទ្រិច ក្នុងមជ្ឈដ្ឋានអាស៊ីតស៊ុលផួរិច។




**- នីត្រូតូលុយអែន** កើតពីប្រតិកម្មជំនួសរវាង តូលុយអែន ជាមួយអាស៊ីតនីទ្រិច ក្នុងមជ្ឈដ្ឋានអាស៊ីតស៊ុលផួរិច។




2,4,6- ទ្រីនីត្រូ តូលុយអែន
( TNT )



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

- **ផេណុល** ជាសមាសធាតុបង់សែន ដែលភ្ជាប់ក្រុមអ៊ីដ្រុកស៊ីល (-OH) ។




ផេណុល




O-មេទីល ផេណុល ឬ គ្រេសុល




2,4,6-ទ្រីនីត្រូ ផេណុល ឬអាស៊ីតពីគ្រិច

*ទង្វើផេណុល*




ក្លរូបង់សែន សូដ្យូមផេណូឡាត




សូដ្យូមផេណូឡាត ផេណុល សូដ្យូមប៊ីកាបូណាត

*លក្ខណៈរូប*

ផេណុល ជាក្រាមគ្មានពណ៌រលាយក្នុងទឹកតិច ចំណុចរលាយ 42°C ចំណុចរំពុះ 181°C ។ សូលុយស្យុងរបស់វាមានលក្ខណៈពុល គេប្រើវាសម្រាប់សម្លាប់មេរោគ។

*លក្ខណៈគីមី*

**-លក្ខណៈដូចអាល់កុលៈ** គឺវាមានប្រតិកម្មជាមួយសូដ្យូម។




**-លក្ខណៈខុសពីអាល់កុលៈ** ប្រតិកម្មជាមួយ NaOH , $Br_2$ , និង អាល់ដេអ៊ីតផរមិច

*ប្រតិកម្មជាមួយបាស NaOH ព្រោះវាមានលក្ខណៈជាអាស៊ីតផេនិច*




*ប្រតិកម្មជំនួសជាមួយប្រូម $Br_2$*




2,4,6-ទ្រីប្រូម៉ូ ផេណុល



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

*ប្រតិកម្មជាមួយអាល់ដេអ៊ីតផរមិចៈ កាតាលីករជាបាសអាល់កាលី*



ផេណុល អាល់ដេអ៊ីតផរមិច O-អ៊ីដ្រុកស៊ី បង់ស៊ីលអាល់កុល

***ប្រតិកម្មកុងដង់កម្ម*** ជាប្រតិកម្មដែលម៉ូលេគុល ពីរ ឬ ច្រើន ធ្វើប្រតិកម្មជាមួយគ្នាដើម្បីបង្កើតជាម៉ូលេគុលធំជាងមុនដោយផ្តាច់ម៉ូលេគុលតូចៗចេញ។



ផ្នែកមួយនៃបាកេលីត

**- អាល់កុលប្រហើរ** ជាសមាសធាតុប្រហើរដែលមានក្រុមអ៊ីដ្រុកស៊ីល (-OH ) ភ្ជាប់នឹងខ្សែកាបូនជាប់វង់បង់សែន។



**បង់ស៊ីល អាល់កុល**



**ផេនីលអេតាណុល**

ទធ្វើបង់ស៊ីលអាល់កុល តាមប្រតិកម្មរវាង បង់ស៊ីល ប្រូម៉ូ ជាមួយស៊ូត។



បង់ស៊ីលប្រូមួ បង់ស៊ីលអាល់កុល

## ២. អាល់ដេអ៊ីតប្រហើរ

ជាសមាសធាតុប្រហើរដែលមានបង្គុំ (-CHO ) ភ្ជាប់នឹងខ្សែកាបូនជាប់វង់បង់សែន។



**- លក្ខណៈរូបៈ** ជាអង្គធាតុរាវគ្មានពណ៌ មិនរលាយក្នុងទឹករាវរលាយនៅ-17ºC និង ពុះនៅ 179ºC ។

**- លក្ខណៈគីមីៈ** ប្រតិកម្មជំនួសប្រូម $Br_2$ (ប្រព្រឹត្តទៅដោយពិបាក)។



បង់សាល់ដេអ៊ីត p-ប្រូម៉ូបង់សាល់ដេអ៊ីត

**- លក្ខណៈជាអាល់ដេអ៊ីតៈ** វាអាចរងអុកស៊ីតតាមសម្រួលដោយ $K_2Cr_2O_7$ ទៅជាអាស៊ីត។



បង់សាលដេអ៊ីត អាស៊ីត បង់សូអ៊ិច



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

**-ធ្វើអាល់ដេអ៊ីត:** តាមប្រតិកម្មជំនួសក្លរលើតូលុយអែន បន្ទាប់មករងអ៊ីដ្រូលីសក្នុងមជ្ឈដ្ឋាន បាស។




តូលុយអែន បង់សាល់ក្លរ បង់សាល់ដេអ៊ីត

## ៣. អាស៊ីតប្រហើរ

ជាសមាសធាតុប្រហើរដែលមានបង្គំនាទី (-COOH ) ភ្ជាប់នឹងវង់បង់សែនមួយឬច្រើន។




**ធ្វើអាស៊ីតប្រហើរ**

*-ធ្វើអាស៊ីតបង់សូអ៊ិច៖* តាមប្រតិកម្មអុកស៊ីតកម្មនៃបង់សាល់ដេអ៊ីត




បង់សាល់ដេអ៊ីត អាស៊ីតបង់សូអ៊ិច

*-ធ្វើអាស៊ីត p-ក្លរ បង់សូអ៊ិច៖* ប្រតិកម្មអុកស៊ីតកម្ម p-ក្លរ តូលុយអែនដោយ $KMnO_4$។




p-ក្លរ តូលុយអែន អាស៊ីត p-ក្លរ បង់សូអ៊ិច

*-ធ្វើអាស៊ីតតេរេផ្តាលិច៖* តាមប្រតិកម្មអុកស៊ីតកម្មនៃ p-ស៊ីឡែនដោយ អុកស៊ីសែននៅសីតុណ្ហភាពខ្ពស់ និងមានកាតាលីករ កូបាល់ (Co ) ។




p-ស៊ីឡែន អាស៊ីតតេរេផ្តាលិច



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys